ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

## ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព

## ២០១៩-២០២៣



ក្រុមប្រឹក្សាសកម្មភាពជនពិការ

ឆ្នាំ ២០១៩

ការបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាសកម្មភាពជនពិការ
សហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
រក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រុមប្រឹក្សាសកម្មភាពជនពិការ ឆ្នាំ២០១៩
បោះពុម្ពនៅរាជធានីភ្នំពេញ

**បម្រាម**

ការបោះពុម្ពឡើងវិញនូវខ្លឹមសារដែលមាននៅក្នុងសៀវភៅផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣នេះ សម្រាប់លក់ ឬគោលបំណងផ្សេងទៀត រួមទាំងការប្រកាសផ្សាយជាសាធារណៈ និងផ្សាយពាណិជ្ជកម្ម ត្រូវបានហាមឃាត់ ក្នុងករណីដែលគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំការអនុញ្ញាតត្រូវដាក់ជូនទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ តាមអាសយដ្ឋានអ៊ីម៉ែល info@dac.org.kh ដោយភ្ជាប់ជាមួយនូវគោលបំណង និងចំនួននៃការផលិតឡើងវិញនោះ។

ឧបត្ថម្ភការកសាងផែនការយុទ្ធសាស្ត្រជាតិដោយ៖

រាជរដ្ឋាភិបាលកម្ពុជា

សហការឧបត្ថម្ភនិងបោះពុម្ពដោយ៖

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព
# ២០១៩-២០២៣

ក្រុមប្រឹក្សាសកម្មភាពជនពិការ

ឆ្នាំ២០១៩

# មាតិកា


បុព្វកថា........................................................................................................................ i
អារម្ភកថា....................................................................................................................... v
១. សេចក្តីផ្តើម.................................................................................................................. ១
២. ចក្ខុវិស័យ.................................................................................................................... ៣
៣. បេសកកម្ម.................................................................................................................... ៣
៤. គោលបំណងនិងគោលដៅ............................................................................................. ៣
៤.១. គោលបំណង............................................................................................................ ៣
៤.២. គោលដៅ................................................................................................................. ៣
៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ........................................................................................................ ៣
៥.១. គោលការណ៍ណែនាំ.................................................................................................. ៤
៥.២. ការវិភាគជាយុទ្ធសាស្ត្រ.............................................................................................. ៤
៥.៣. ទិសដៅជាយុទ្ធសាស្ត្រ................................................................................................. ៩
៦. សកម្មភាពការងារ........................................................................................................ ២០
៦.១. ដំណាក់កាលសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣.................................................................................................................... ២០
៦.២. ការបង្កើតកម្មវិធីនិងការកសាងផែនការសកម្មភាព........................................................ ២២
៧. ធនធានហិរញ្ញវត្ថុ......................................................................................................... ២៣
៨. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ......................................................................... ២៣
៨.១. គោលការណ៍នានា.................................................................................................... ២៤
៨.២. វិធីសាស្ត្រ.................................................................................................................. ២៤
៨.៣. ការគ្រប់គ្រងនិងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត..................................................... ២៥
៩. សេចក្តីសន្និដ្ឋាន........................................................................................................... ២៦
សន្ទានុក្រម..................................................................................................................... ២៧

# ជនមានពិការភាពកម្ពុជា

មានចំនួន ៥២៤ ពាន់នាក់

ស្មើ ៤%

# នៃប្រជាជនកម្ពុជាសរុប

ឈរលើស្មារតីនៃការទទួលខុសត្រូវខ្ពស់សម្រាប់ជនមានពិការភាព រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យគឺ **“ជនមានពិការភាព និងក្រុមគ្រួសារ មានគុណភាពជីវិតល្អ ចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យនិងការអភិវឌ្ឍ”។**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ



# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ប្រទេសជាតិ ដោយបន្តប្តេជ្ញាថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ កំណើនសេដ្ឋកិច្ចដោយឈរលើមូលដ្ឋានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ សិទ្ធិរបស់ជនមានពិការភាពក៏ត្រូវបានការពារដោយច្បាប់ជាតិនិងអន្តរជាតិ ក្នុងគោលបំណងការពារសិទ្ធិ សេរីភាព ការពារផលប្រយោជន៍ ទប់ស្កាត់ កាត់បន្ថយ លុបបំបាត់ ការរើសអើងចំពោះជនមានពិការភាព ដើម្បីធានាដល់សិទ្ធិស្មើភាពគ្នានៃសកម្មភាពក្នុងសង្គមរវាងជនមានពិការភាពនិងមិនមានពិការភាព។

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានខិតខំដាក់ឲ្យដំណើរការការបើកផ្តល់របបគោលនយោបាយជូនចំពោះជនមានពិការភាពក្រីក្រនៅតាមសហគមន៍បានចំនួន១១ ៦២៨នាក់នៅខេត្តចំនួន១០ រួមមាន ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង ប៉ៃលិន កំពង់ចាម កណ្តាល កំពង់ធំ កំពង់ស្ពឺ បាត់ដំបង និងពោធិ៍សាត់ ដែលជាការរួមចំណែកកាត់បន្ថយការលំបាករបស់ជនមានពិការភាពក្រីក្រ ហើយរាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាពង្រឹងការលើកកម្ពស់សុខុមាលភាព ព្រមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីបម្រើផលប្រយោជន៍របស់ជនមានពិការភាពតាមលទ្ធភាពទ្រទ្រង់នៃថវិកាជាតិ។ ការជ្រើសរើសជនមានពិការភាពឲ្យចូលបម្រើការងារតាមក្រសួងស្ថាប័ន គឺបានចំនួន២ ៣៩៣នាក់ ក្នុងចំណោមក្រសួង ស្ថាប័ន៤០ ហើយតាមវិស័យឯកជនគឺអនុវត្តបានចំនួន ៣ ៤៧៥នាក់ ក្នុងចំណោមក្រុមហ៊ុនចំនួន៧៧ គិតត្រឹមឆ្នាំ២០១៨។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមូលនិធិជនពិការ ដើម្បីជាផ្នែកធានាការផ្តល់សន្តិសុខប្រាក់ចំណូលសម្រាប់ជនមានពិការភាព ហើយបានសហការជាមួយអង្គការដៃគូផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនមានពិការភាពចំនួន៣៨៧ ៦៥៨នាក់ ក្នុងនោះស្តារលទ្ធភាពពលកម្មកាយសម្បទាបានចំនួន១៣៧ ២៧៩នាក់ សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្របានចំនួន២៥០ ៣៧៩នាក់។ ទន្ទឹមនឹងនេះ ជនមានពិការភាពដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ក៏បានទទួលការឧបត្ថម្ភថ្លៃអាហារនិងថ្លៃធ្វើដំណើរទៅមកផងដែរ។ ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សេវាសហគមន៍ជូនជនមានពិការភាពដូចជាការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណបចំនួន២៦ ៧០៣នាក់។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការដែលជាយន្តការសម្របសម្រួលថ្នាក់ជាតិនិងពិគ្រោះយោបល់លើបញ្ហាពិការភាព បានអនុវត្តនូវតួនាទីប្រកបដោយការទទួលខុសត្រូវខ្ពស់លើការបង្កើនការយល់ដឹងនិងបញ្ជ្រាបបញ្ហាពិការភាពទៅក្នុងគ្រប់វិស័យ មានជាអាទិ៍វិស័យសង្គមកិច្ច សេដ្ឋកិច្ច សុខាភិបាល អប់រំ ទេសចរណ៍ យេនឌ័រ កសិកម្ម ការងារ កីឡា សិល្បៈ វប្បធម៌ សាសនា ព័ត៌មាន យុត្តិធម៌ ជាដើម។ លើសពីនេះទៀតក្រុមប្រឹក្សាសកម្មភាពជនពិការបានជំរុញយ៉ាងសកម្មដល់គ្រប់ក្រសួង ស្ថាប័ន និងវិស័យឯកជនឲ្យអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងទសវត្សជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "*ធ្វើឲ្យសិទ្ធិក្លាយ*

*ជាការពិត* ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថនៃការទទួលស្គាល់ទាំងសកម្មភាពនិងសំឡេងរបស់ជនមានពិការភាពនៅក្នុងសង្គម ពិសេស បំបាត់នូវឧបសគ្គរាំងនានាផ្អែកលើគោលការណ៍សិទ្ធិស្មើគ្នា។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យស្តីពីការផ្តល់ប្រាក់រង្វាន់ដល់ជ័យលាភីជនពិការក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស្ទើស្បាល់អូឡាំពិក និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក និងគ្រូបង្វឹកជំនួយ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិជនមានពិការភាព និងលើកទឹកចិត្តក្នុងការចូលរួមប្រកួតប្រជែងមុខជំនាញនិងការប្រកួតកីឡាស្ទើស្បាល់អូឡាំពិកជាលក្ខណៈជាតិនិងអន្តរជាតិ។ បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ត្រូវបានកសាងនិងដាក់ឲ្យអនុវត្តចំពោះគម្រោងសាងសង់និងការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សំណង់ អគារផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពគ្រប់ប្រភេទអាចចល័តទី ចេញចូល ឡើងចុះ និងប្រើប្រាស់ដោយងាយស្រួលប្រកបដោយសុវត្ថិភាពនិងគ្មានឧបសគ្គ។

ការបង្កើតវេទិកាជជែកពិភាក្សារវាងអ្នកនយោបាយ មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជាជាមួយជនមានពិការភាពនិងសង្គមស៊ីវិល ត្រូវបានរៀបចំឡើងតាមរយៈការផលិតកម្មវិធីទូរទស្សន៍ក្នុងកិច្ចពិភាក្សាស្តីពីពិការភាពដោយបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជន អំពីតម្រូវការនិងបញ្ហានានាដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ជនមានពិការភាព។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលកម្ពុជាតែងបានផ្តល់ឱកាសឲ្យជនមានពិការភាពបានចូលរួមក្នុងសកម្មភាពសង្គម តាមរយៈសកម្មភាពកីឡា សិល្បៈ វប្បធម៌ និងការប្រកួតប្រជែងដណ្តើមជ័យលាភី ព្រមទាំងបានប្រារព្ធទិវាជនមានពិការភាពកម្ពុជានិងទិវាជនមានពិការភាពអន្តរជាតិ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់គោលការណ៍ដល់ឧស្សាហកម្មអាកាសចរណ៍ ដែលកំពុងធ្វើធុរកិច្ចនៅព្រះរាជាណាចក្រកម្ពុជា រៀបចំគោលនយោបាយឬគោលការណ៍របស់ក្រុមហ៊ុនឡើងវិញដើម្បីផ្តល់ភាពអនុគ្រោះ ពិសេស ការផ្តល់សេវាកម្មដល់ជនមានពិការភាព ដោយបន្ធូរបន្ថយជាអតិបរមាឬអាចលើកលែងទាំងស្រុងនូវកម្រៃសេវាចាំបាច់មួយចំនួនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានបង់ពន្ធជំនួសការនាំចូលឧបករណ៍ជំនួយសម្រាប់ស្តារលទ្ធភាពពលកម្មដល់ជនមានពិការភាពដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបង់ថ្លៃជំនួសសម្រាប់ការពិនិត្យព្យាបាលជំងឺដល់ជនមានពិការភាពនិងចាស់ជរាមានជីវភាពលំបាកគ្មានទីពឹងនៅតាមមន្ទីរពេទ្យនិងមណ្ឌលសុខភាពទាំងអស់ក្នុងគោលបំណងរួមចំណែកថែទាំនិងពង្រឹងគុណភាពសេវាសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានកាន់តែទូលំទូលាយ។

ជារួម កត្តាសន្តិភាពនិងស្ថិរភាពនយោបាយពេញលេញដែលកម្ពុជាកំពុងមានសព្វថ្ងៃជាកាលានុវត្តភាពសម្រាប់អភិវឌ្ឍវិស័យពិការភាពនៅកម្ពុជាប្រកបដោយភាពរឹងមាំនិងវិជ្ជមាន ដោយបានអនុញ្ញាតឲ្យកម្ពុជាមានលទ្ធភាពគិតគូរដល់ជនងាយរងគ្រោះពិសេសជនមានពិការភាពទទួលបានការគាំពារក្នុងរូបភាពផ្សេងៗដូចជាការបង្កើតមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទានិងវេជ្ជសាស្ត្រ រោងចក្រផលិតឧបករណ៍អវយវៈ

សិប្បនិម្មិតនិងរណប មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនមានពិការភាព មជ្ឈមណ្ឌលបុរីទារក និងកុមារជាតិ មជ្ឈមណ្ឌលថែទាំនិងស្តារនីតិសម្បទាជនវិបល្លាសស្មារតីជាដើម។

កន្លងមក ផ្នត់គំនិតនៅក្នុងសង្គមជាទូទៅតែងមានជំនឿឬយល់ឃើញថាជនមានពិការភាពគឺជាមនុស្សអពមង្គលឬជាមនុស្សដែលបានសាងបាបកម្មពីជាតិមុន ដែលធ្វើឲ្យជនមានពិការភាពទទួលរងការរើសអើង ស្ទើរតែពុំហ៊ានចេញពីផ្ទះឬចូលរួមក្នុងសកម្មភាពសង្គម។ ផ្ទុយទៅវិញ តាមការវិភាគផ្នែកវេជ្ជសាស្ត្រ ពិការភាពអាចកើតឡើងទៅលើមនុស្សទូទៅគ្រប់វ័យ នៅពេលដែលពួកគេមានការធ្វេសប្រហែសទៅលើជំងឺមួយចំនួន ដូចជាជំងឺកញ្ជ្រឹល ទឹកនោមផ្អែម រលាកស្រោមខួរក្បាល ភ្នែកឡើងបាយ គាំងឬខ្សោយបេះដូង លើសសម្ពាធឈាម ខូចប្រព័ន្ធតម្រងនោម ជំងឺប្រព័ន្ធផ្លូវដង្ហើម ហង់សិន រលាកសន្លាក់ ភ្លេចភ្លាំង ជំងឺផ្លូវចិត្តរ៉ាំរ៉ៃ រលាកថ្លើម ជំងឺហ៊ីវអេដស៍ កង្វះអាហារូបត្ថម្ភ និងជំងឺបណ្តាលមកពីតំណពូជមួយចំនួន។ លើសពីនេះទៅទៀត គ្រោះថ្នាក់ចរាចរណ៍ យុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម គ្រោះថ្នាក់ការងារ អំពើហិង្សា គ្រោះមហន្តរាយជាដើម ក៏ជាមូលហេតុបណ្តាលឲ្យមានពិការភាពផងដែរ។

ឈរលើស្មារតីនៃការទទួលខុសត្រូវខ្ពស់សម្រាប់ជនមានពិការភាពនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យគឺ "***ជនមានពិការភាពនិងក្រុមគ្រួសារមានគុណភាពជីវិតល្អនិងចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យនិងការអភិវឌ្ឍ***"។

ផ្អែកលើចក្ខុវិស័យខាងលើនិងឈរលើមូលដ្ឋានការពារនិងលើកកម្ពស់សិទ្ធិជនមានពិការភាព រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ដែលជាដំណាក់កាលទី២ សម្រាប់កំណត់ចក្ខុវិស័យនិងផែនទី ដើម្បីបន្តជំរុញសង្គមមួយឆ្ពោះទៅរកការលុបបំបាត់ឧបសគ្គរាំងនានាដល់ជនមានពិការភាព ស្របតាមពាក្យស្លោកសកល "***ធ្វើឲ្យសិទ្ធិក្លាយជាការពិត***"។

ឯកសារនេះរៀបចំឡើងក្នុងគោលបំណងដើម្បីកំណត់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់វិស័យពិការភាព ក្នុងការធានាឲ្យជនមានពិការភាពទទួលបានការបង្កើនការងារនិងសន្តិសុខសេដ្ឋកិច្ច ការបង្កើនលទ្ធភាពទទួលបានសេវាសុខភាពនិងស្តារលទ្ធភាពពលកម្ម លទ្ធភាពទទួលបានការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការបង្កលក្ខណៈងាយស្រួល ការចូលរួមដោយសមភាព លទ្ធភាពទទួលបានសេវាយុត្តិធម៌និងសិទ្ធិសេរីភាព ការធានាសមភាពយេនឌ័រ ការកាត់បន្ថយហានិភ័យនិងផលប៉ះពាល់បង្កដោយគ្រោះមហន្តរាយ ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ និងធានាថាមានទិន្នន័យនិងស្ថិតិពិការភាពដែលអាចទុកចិត្តនិងប្រៀបធៀបបាន។

ដើម្បីធានានូវស័ក្តិសិទ្ធិភាពលើឯកសារដ៏មានសារៈសំខាន់នេះ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ ត្រូវបានរៀបចំឡើងនិងសម្របសម្រួលដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយរវាងក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស ជនមានពិការភាព។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា រួមទាំងជនមានពិការភាពដែលបានចូលរួមជួយគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ សម្រាប់រួមចំណែកធ្វើឲ្យស្ថានភាពរបស់ជនមានពិការភាពនៅកម្ពុជាមានវឌ្ឍនភាពគួរជាទីមោទនៈ។

ជាថ្មីម្តងទៀត ខ្ញុំសូមជំរុញនិងសង្ឃឹមយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ នឹងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានជាលំដាប់នូវកម្រិតជីវភាពនិងគុណភាពជីវិតរបស់ជនមានពិការភាពកម្ពុជាគ្រប់រូប។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**ហ៊ុន សែន**






ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

# អារម្ភកថា

នៅព្រះរាជាណាចក្រកម្ពុជា ការងារពិការភាពគឺជាបញ្ហាប្រឈមមួយដែលត្រូវយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយបរិយាបន្ននិងចីរភាព។ ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងដោះស្រាយយ៉ាងយកចិត្តទុកដាក់ តាមរយៈការរៀបចំ កសាង អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព បង្កើតយន្តការ និងកម្មវិធីគាំទ្រនានាជាច្រើន។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ គឺជាសមិទ្ធផលនិងជាប្រវត្តិសាស្ត្រថ្មីមួយទៀតក្នុងវិស័យពិការភាព បន្ទាប់ពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ បានបញ្ចប់ទៅដោយមានប្រសិទ្ធភាព ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជា**ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ**។

ឯកសារផែនការយុទ្ធសាស្ត្រជាតិ២០១៩-២០២៣ រៀបចំឡើងដើម្បីសម្រេចនូវគោលបំណងដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងទសវត្សជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ ***"ធ្វើឲ្យសិទ្ធិក្លាយជាការពិត"*** ព្រមទាំងគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥។ ឯកសារនេះ បានលើកឡើងយ៉ាងលម្អិតនូវគោលនយោបាយជាអាទិភាព ទិសដៅជាយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗសម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងបញ្ហាប្រឈមនានាក្នុងវិស័យពិការភាព សំដៅលើកកម្ពស់សមត្ថភាពក្រសួងស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ក្នុងទិសដៅបង្កើតកាលានុវត្តភាពជីវភាពសមស្របសម្រាប់ជនមានពិការភាពក្នុងការកាត់បន្ថយភាពក្រីក្រនិងការចូលរួមរបស់ជនមានពិការភាពដោយពេញលេញនៅក្នុងសង្គម។

ការកំណត់ទិសដៅនិងផែនការដែលត្រូវអនុវត្តផ្តោតលើគោលដៅជាយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១- បង្កើនការងារនិងសន្តិសុខសេដ្ឋកិច្ច ពោលគឺកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់កំណើនការងារសមស្របនិងពង្រឹងពង្រីកអាជីពនិងមុខរបរដើម្បីបង្កើនជីវភាពរស់នៅបានសមរម្យ ព្រមទាំងធានាការទទួលបានប្រព័ន្ធជំនួយសង្គម។

២- បង្កើនលទ្ធភាពទទួលសេវាសុខភាពនិងស្តារលទ្ធភាពពលកម្មតាមរយៈការបង្កើនការផ្តល់សេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ដោយគ្មានការរើសអើងប្រកបដោយគុណភាពនិងចីរភាព និងការផ្តល់សេវាស្តារលទ្ធភាពពលកម្មឲ្យបានសមស្រប។

៣- ផ្តល់លទ្ធភាពទទួលបានការអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការលើកកម្ពស់ការអប់រំដល់ជនមានពិការភាពប្រកបដោយគុណភាព បរិយាបន្ន សមភាព សមធម៌ និងពេញមួយជីវិត ព្រមទាំងបណ្តុះបណ្តាលជំនាញដល់ជនមានពិការភាព។

៤- អនុវត្តការបង្កលក្ខណៈងាយស្រួលដោយកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អមធ្យោបាយដឹកជញ្ជូនសាធារណៈ ព្រមទាំងកែលម្អមធ្យោបាយទំនាក់ទំនង ចំណេះដឹង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងឧបករណ៍និងសេវាកម្មផ្សេងៗទៀតសម្រាប់ជនមានពិការភាព។

៥- បង្កើនការចូលរួមដោយសមភាព ដើម្បីលើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងជីវិតសាធារណៈ នយោបាយ វប្បធម៌ សិល្បៈ សាសនា កីឡា ការសម្រាកលំហែ និងសកម្មភាពផ្សេងៗ។

៦. បង្កើនលទ្ធភាពទទួលបានសេវាយុត្តិធម៌និងសិទ្ធិសេរីភាព ដើម្បីលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌សំដៅការពារសេរីភាពនិងសន្តិសុខបុគ្គលដល់ជនមានពិការភាព ជាពិសេស ស្ត្រីនិងក្មេងស្រីមានពិការភាព។

៧. ធានាសមភាពយេនឌ័រ តាមរយៈការលើកកម្ពស់សមភាពយេនឌ័រ ភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីមានពិការភាព។

៨. កាត់បន្ថយហានិភ័យនិងផលប៉ះពាល់បង្កដោយគ្រោះមហន្តរាយ ក្នុងបុរេវិនិច្ឆ័យហានិភ័យគ្រោះមហន្តរាយ អំឡុងពេលគ្រប់គ្រងស្ថានភាពនិងអន្តរាគមប្រកបដោយប្រសិទ្ធភាព និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។

៩. ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ និងធានាថាមានទិន្នន័យនិងស្ថិតិពិការភាពដែលអាចទុកចិត្តនិងប្រៀបធៀបបាន។

ឯកសារនេះ ជាក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជាតិ និងជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យមសម្រាប់ការអភិវឌ្ឍសុខុមាលភាពជនមានពិការភាពនៅកម្ពុជា ដែលបង្ហាញពីគំរូសកម្មភាព លទ្ធផលរំពឹងទុក ស្ថាប័នអនុវត្ត ពេលវេលា និងប្រភពធនធាន ព្រមទាំងយន្តការតាមដានដើម្បីធានាឲ្យការអនុវត្តប្រកបដោយជោគជ័យ។ ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ មានលក្ខណៈបត់បែនដែលអនុញ្ញាតឲ្យរាជរដ្ឋាភិបាលកម្ពុជាអាចធ្វើបច្ចុប្បន្នកម្ម និងកែលម្អគោលបំណងឬគោលដៅយុទ្ធសាស្ត្រស្របទៅតាមការវិវត្តសេដ្ឋកិច្ចនិងសង្គម ព្រមទាំងអនុញ្ញាតឲ្យមានក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ទៅតាមដំណាក់កាលជាដំហានៗ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ត្រូវបានកសាងឡើងដោយមានការផ្តល់ធាតុចូលពីក្រសួងស្ថាប័នក្នុងជួររាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍ សង្គមស៊ីវិល អ្នកជំនាញផ្នែកពិការភាពជាច្រើន ពិសេសជនមានពិការភាពខ្លួនឯងផ្ទាល់ ដើម្បីបម្រើឲ្យឧត្តមប្រយោជន៍របស់ជនមានពិការភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះកិច្ចសហការដ៏ល្អរបស់ក្រសួងស្ថាប័ន សមាជិក សមាជិកាក្រុមប្រឹក្សាសកម្មភាពជនពិការ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អ្នកជំនាញផ្នែកពិការភាព និងជនមានពិការភាពជាពិសេសថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងលេចចេញជារូបរាងឡើង។

ថ្ងៃ ចន្ទ ៧រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

**វង សូត**

## ១- សេចក្តីផ្តើម

១- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ត្រូវបានបញ្ចប់ជាស្ថាពរដោយជោគជ័យ តាមរយៈកិច្ចសហការល្អរវាងក្រសួងស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិ អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍ និងជនមានពិការភាពខ្លួនឯងផ្ទាល់ ដោយមានការទទួលខុសត្រូវខ្ពស់ក្នុងឆន្ទៈឈានទៅសម្រេចឲ្យខាងតែបាននូវ យុទ្ធសាស្ត្រទាំង១០ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ទន្ទឹមនឹងនេះ កត្តាសន្តិភាពគឺជាកាលានុវត្តភាពមួយដែលបានរួមចំណែកដល់ស័ក្តិសិទ្ធិភាពនៃការជំរុញឲ្យសង្គមកម្ពុជាបោះជំហានឆ្ពោះទៅរកការលុបបំបាត់ឧបសគ្គដើម្បីសង្គមមួយសម្រាប់យើងទាំងអស់គ្នា។

២- ជនងាយរងគ្រោះដែលមានពិការភាពតែងតែជួបឧបសគ្គដោយមិនបានចូលរួមពេញលេញក្នុងសកម្មភាព ជីវភាពប្រចាំថ្ងៃ កន្លែងធ្វើការ និងទីសាធារណៈផ្សេងៗ ព្រមទាំងវិសមភាពពីសង្គម ដែលត្រូវបានកែប្រែជាជំហានៗចាប់តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន។ ការរើសអើងពីសង្គមដែលជនមានពិការភាពតែងជួបប្រទះទាំងផ្នែកកាយសម្បទានិងហិរញ្ញវត្ថុ ត្រូវបានកាត់បន្ថយក្នុងកម្រិតខ្ពស់គួរឲ្យកត់សម្គាល់ ការបង់ប្រាក់ថ្លៃសេវាសុខភាពក៏ត្រូវបានរដ្ឋទទួលបន្ទុកបង់ជំនួស ការផ្តល់សេវាសុខាភិបាលក៏ត្រូវបានយកចិត្តទុកដាក់ពិនិត្យព្យាបាលដោយការទទួលខុសត្រូវខ្ពស់ កុមារមានពិការភាពក៏ត្រូវបានបង្កើនឱកាសឲ្យចុះឈ្មោះចូលរៀននិងបានធ្វើបរិយាបន្នថ្នាក់អប់រំពិសេស ដែលជាឱកាសឲ្យជនមានពិការភាពឈានទៅបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា រួមទាំងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានមុខរបរអាចចិញ្ចឹមជីវិតខ្លួនឯងបានផងដែរ។ កត្តានេះ បាននាំឲ្យជនមានពិការភាពមានលទ្ធភាពក្នុងការចូលរួមចំណែកបង្កើនផលិតភាពសេដ្ឋកិច្ចឬទទួលបានអត្ថប្រយោជន៍ពីកត្តាសេដ្ឋកិច្ច។

៣- ការទប់ស្កាត់មូលហេតុចម្បងៗដែលនាំឲ្យមានពិការភាព តាមរយៈការបង្កើនការយល់ដឹងពីគ្រោះថ្នាក់នៃយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ការផ្តល់អាហារូបត្ថម្ភបានគ្រប់គ្រាន់ ការអប់រំច្បាប់ចរាចរណ៍ដើម្បីបង្ការគ្រោះថ្នាក់ចរាចរណ៍ ការបង្កើនការយល់ដឹងពីសុវត្ថិភាពគ្រោះថ្នាក់ការងារ ការថែរក្សាសុខភាពក្នុងពេលស្ត្រីមានគភ៌និងក្រោយសម្រាលកូន ត្រូវបានអនុវត្តយ៉ាងសកម្មក្នុងយុទ្ធសាស្ត្របង្ការពិការភាព។

៤- សមិទ្ធផលទាំងនេះ គឺពិតជាមិនអាចបដិសេធបាន និងជាមោទនភាពសម្រាប់រាជរដ្ឋាភិបាលក៏ដូចជាជនមានពិការភាពកម្ពុជា ពិសេសបើធៀបទៅនឹងស្ថានភាពសេដ្ឋកិច្ចនិងសង្គមនៅកម្រិតសូន្យដែលរាជរដ្ឋាភិបាលបានទទួលពីឆ្នាំ១៩៧៩។ សមិទ្ធផលនាពេលបច្ចុប្បន្នបានឆ្លើយតបទៅនឹងតម្រូវការពិសេស និងមានប្រសិទ្ធភាពយ៉ាងជាក់លាក់ដែលទទួលបានការសាទរពីសង្គមនិងជនមានពិការភាពខ្លួនឯងផ្ទាល់។

៥- បើទោះបីជារាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលដូចខាងលើនេះក្តី ក៏នៅមានបញ្ហាប្រឈមមួយចំនួនទៀតដែលនៅមិនទាន់ដោះស្រាយចប់នៅឡើយ ដែលទាមទារឲ្យមានកិច្ចប្រតិបត្តិការបន្តដើម្បីឈានទៅសម្រេចបាននូវគោលបំណងកំណត់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធានាឲ្យសុខុមាលភាពរបស់ជនមានពិការភាពមានចំណូលដូចជនទូទៅតាមសេចក្តីប្រាថ្នានិងការខិតខំរបស់រាជរដ្ឋាភិបាល ដែលប្រែក្លាយឋានៈរបស់កម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

៦- គោលបំណងនៃការរៀបចំឯកសារនេះ គឺដើម្បីកំណត់អាទិភាពយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យពិការភាពដើម្បីធ្វើការបន្សុំ បញ្ជ្រាប និងធ្វើបរិយាបន្នបញ្ហាពិការភាពទៅក្នុងគ្រប់វិស័យដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃយុទ្ធសាស្ត្រទាំងឡាយ ទាំងក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារ

សង្គម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬរបៀបវារៈឆ្នាំ២០៣០ ក៏បានប្តេជ្ញាចិត្តថា **"មិនមាននរណាម្នាក់ត្រូវបានទុកចោល"** ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពនិងការពារផលប្រយោជន៍ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនមានពិការភាព ពិសេសការគិតគូរអំពីការស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ព្រមទាំងធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញនិងដោយស្មើភាពនៅគ្រប់សកម្មភាពនានាក្នុងសង្គម ស្របតាមឆន្ទៈរបស់រដ្ឋសភាជាតិដែលបានអនុម័តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ ហើយដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ រួមជាមួយឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់វិស័យពិការភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនមានពិការភាព ផ្តល់ឱកាសស្មើគ្នាក្នុងការចូលរួមលើគ្រប់វិស័យ រួមទាំងសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។

៧- កម្ពុជាជាប្រទេសគំរូក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ក្នុងការអនុវត្តទសវត្សជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២(យុទ្ធសាស្ត្រអ៊ីនឈាន់ **"ធ្វើឲ្យសិទ្ធិក្លាយជាការពិត"**)។ យុទ្ធសាស្ត្រអ៊ីនឈាន់ផ្តល់ឲ្យតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនិងពិភពលោក នូវឯកសារលើកដំបូងដែលមានការព្រមព្រៀងថ្នាក់តំបន់ក្នុងការដាក់បញ្ចូលពិការភាពទៅក្នុងគោលដៅអភិវឌ្ឍន៍។

៨- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ បានផ្តោតលើការអភិវឌ្ឍសុខុមាលភាពជនមានពិការភាព តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសុខុមាលភាពនិងលើកកម្ពស់សិទ្ធិជនមានពិការភាព រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាពឲ្យបានជាក់លាក់ ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងបង្កើតមុខរបរ កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនមានពិការភាពក្រីក្រនៅតាមសហគមន៍ រៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់បម្លាស់ទី ព្រមទាំងការជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងពិការភាព។

៩- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ បានរៀបចំឡើងដោយផ្អែកទៅលើការឆ្លុះបញ្ចាំងការអនុវត្តផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម២០០៩-២០១១ និងបន្តរហូតដល់ឆ្នាំ២០១៣ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី១ឆ្នាំ២០១៤-២០១៨។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ គឺជាមូលដ្ឋានគ្រឹះក្នុងការពន្លឿនការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ផែនការអភិវឌ្ឍន៍ជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងទសវត្សជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា។

១០- ការកសាងឯកសារផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា និងជនមានពិការភាព។ ដៃគូពិភាក្សាទាំងអស់នេះ បានរួមគ្នាគិតគូរពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ ដើម្បីធានាថារាល់ទស្សនៈនិងតម្រូវការរបស់ជនមានពិការភាពត្រូវបានដាក់បញ្ចូលក្នុងផែនការនេះ។

## ២- ចក្ខុវិស័យ

ជនមានពិការភាពនិងក្រុមគ្រួសារមានគុណភាពជីវិតល្អនិងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យនិងការអភិវឌ្ឍ។

## ៣- បេសកកម្ម

ជំរុញការចូលរួមពីក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា រួមទាំងជនមានពិការភាពដើម្បីធ្វើបរិយាបន្នពិការភាពទៅក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ឈានទៅសម្រេចបាននូវគុណភាពជីវិតរបស់ជនមានពិការភាពប្រកបដោយចីរភាព។

## ៤- គោលបំណងនិងគោលដៅ

### ៤.១- គោលបំណង

- ធ្វើឲ្យគុណភាពជីវិតរបស់ជនមានពិការភាពនិងស្ថានភាពគ្រួសារមានភាពប្រសើរឡើង គោរពសេចក្តីថ្លៃថ្នូរពីកំណើត និងការរស់នៅដោយឯករាជ្យ ព្រមទាំងសុខុមាលភាពពេញលេញ។
- លើកកម្ពស់ភាពស្មើគ្នាចំពោះមុខច្បាប់ ទទួលបានសេវាយុត្តិធម៌ ចាកផុតពីទារុណកម្ម រំលោភបំពាន កេងប្រវ័ញ្ច អំពើហិង្សា និងទទួលបានដំណោះស្រាយគ្រាមានអាសន្ន ព្រមទាំងលើកស្ទួយសមភាពស្ត្រីមានពិការភាព កុមារមានពិការភាព និងជនមានពិការភាពគ្រប់ប្រភេទ។

### ៤.២- គោលដៅ

- ផ្តល់សេវាគាំពារសង្គម ស្តារលទ្ធភាពពលកម្ម អប់រំ កីឡា បណ្តុះបណ្តាលវិជ្ជាជីវៈ ការងារ អាជីពនិងសេវាកម្មនានាជួយជនមានពិការភាព។
- កែលម្អឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង។
- ផ្តល់សិទ្ធិអំណាច តាមរយៈការចូលរួមគ្រប់សកម្មភាពនៃការសម្រេចចិត្តនិងការធ្វើនយោបាយរបស់ជនមានពិការភាពក្នុងសង្គម។

## ៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមនិងរបបប្រល័យពូជសាសន៍និងរងនូវមហាវិនាសកម្មដែលបានបន្សល់ទុកផលវិបាកជាច្រើន ដែលក្នុងនោះមានអត្រាជនមានពិការភាពខ្ពស់។ ក្រៅពីនេះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពងាយរងគ្រោះមួយចំនួនដែលនាំឲ្យមានពិការភាព ដូចជាគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងៗទៀត។

ជននិងកុមារមានពិការភាព ត្រូវបានធ្វើបរិយាបន្នទៅក្នុងគ្រប់សកម្មភាពអភិវឌ្ឍ ដោយមិនបានទុកជនមានពិការភាពឲ្យនៅដាច់ដោយឡែកនិងធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន។ ការយល់ឃើញរបស់សង្គមចំពោះជនមានពិការភាព ក្នុងការទទួលស្គាល់សកម្មភាពនិងសំឡេងរបស់ពួកគេ ពិតជានឹងនាំមកនូវការលើកកម្ពស់ដល់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាបន្ន។ ជននិងកុមារមានពិការភាពមានសមត្ថភាព

គ្រប់គ្រាន់ក្នុងការយកឈ្នះនូវរាល់ឧបសគ្គរាំងផ្សេងៗដោយខ្លួនឯង។ ដូចនេះ ការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យ ដោយផ្អែកលើគោលការណ៍សិទ្ធិស្មើភាពគ្នា នឹងធ្វើឲ្យជីវិតរបស់ជនមានពិការភាពបានប្រសើរឡើង។

## ៥.១- គោលការណ៍ណែនាំ

១- គោរពនូវសេចក្តីថ្លៃថ្នូរស្វ័យភាពរបស់បុគ្គល ដែលរួមមានទាំងសេរីភាពការជ្រើសរើសដោយខ្លួនឯងនិងឯករាជ្យភាពនៃបុគ្គល។

២- មិនរើសអើង។

៣- ជំរុញការចូលរួមពេញលេញប្រកបដោយប្រសិទ្ធភាពនិងការដាក់បញ្ចូលទៅក្នុងសង្គម។

៤- គោរពភាពផ្សេងគ្នានិងទទួលយកជនមានពិការភាពជាផ្នែកនៃភាពចម្រុះមនុស្សជាតិនិងមនុស្សធម៌។

៥- ផ្តល់ឱកាសស្មើគ្នា។

៦- ផ្តល់សម្របសម្រួលសមស្រប។

៧- លើកកម្ពស់សមភាពរវាងបុរសនិងស្ត្រី។

៨- គោរពសមត្ថភាពវិវត្តរបស់កុមារមានពិការភាព និងការគោរពសិទ្ធិកុមារមានពិការភាពក្នុងការការពារអត្តសញ្ញាណរបស់ខ្លួន។

៩- ការពារសិទ្ធិនិងសេរីភាពរបស់ជនមានពិការភាព។

១០- ការពារផលប្រយោជន៍របស់ជនមានពិការភាព។

១១- ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនមានពិការភាព។

១២- ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីជានាលទ្ធភាពពលកម្មក្នុងការចូលរួមពេញលេញនិងដោយស្មើភាពនៃជនមានពិការភាពក្នុងសកម្មភាពនានារបស់សង្គម។

## ៥.២- ការវិភាគជាយុទ្ធសាស្ត្រ

ដើម្បីឲ្យមានការឆ្លើយតបជាមួយគោលបំណងនិងអាទិភាពនៃលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ ឯកសារសំខាន់ៗមួយចំនួនត្រូវបានលើកយកមកពិចារណានៅពេលធ្វើការវិភាគជាយុទ្ធសាស្ត្រនេះ។

ឯកសារទាំងនោះរួមមាន ៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- ច្បាប់ភូមិបាល ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥
- ច្បាប់ស្តីពីការអប់រំ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ H8

- ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩
- ច្បាប់ស្ដីពីការបង្ការនិងការពន្លត់អគ្គិភ័យដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៧ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៣
- ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៥
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥
- ច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥
- ច្បាប់ស្ដីពីស្ថិតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥
- ច្បាប់ស្ដីពីសញ្ជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨
- អនុសញ្ញាស្ដីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ដែលអង្គការសហប្រជាជាតិបានអនុម័តនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៧ និង ដែលរាជរដ្ឋាភិបាលបានផ្ដល់សច្ចាប័នតាមរយៈការប្រកាសដាក់ឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៧ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩
- អនុសញ្ញាស្ដីពីសិទ្ធិជនពិការ ដែលអង្គការសហប្រជាជាតិបានអនុម័តនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ និងដែលរាជរដ្ឋាភិបាលបានផ្ដល់សច្ចាប័នតាមរយៈការប្រកាសដាក់ឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២
- យុទ្ធសាស្ត្រអ៊ីនឈាន់"**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**" អង្គការសហប្រជាជាតិ គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច សង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ប៉ាងកក ខែវិច្ឆិកា ឆ្នាំ២០១២
- ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានដាក់ឲ្យអនុវត្ត ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់ឲ្យអនុវត្ត ខែកញ្ញា ឆ្នាំ២០១៨
- គោលនយោបាយស្ដីពីការអប់រំបរិយាបន្ន បានដាក់ឲ្យអនុវត្ត នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨
- ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ បានប្រកាសដាក់ឲ្យអនុវត្ត នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨
- គោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ២០១៦-២០២៦ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦
- គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

- គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ២០១៥-២០២៥ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ បានប្រកាសដាក់ឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧១៩/០១១ នៅចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩
- អនុក្រឹត្យលេខ១០៨.អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ
- អនុក្រឹត្យលេខ១១៨.អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ
- អនុក្រឹត្យលេខ១៣៧.អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- អនុក្រឹត្យលេខ២១៦.អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ

ការវិភាគ "ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង" នៃស្ថានភាពពិការភាពនៅកម្ពុជាបានធ្វើឡើងតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើនរួមមាន ក្រសួងស្ថាប័ន កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និងជនមានពិការភាព។ លទ្ធផលពីការវិភាគ"ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង" ត្រូវបានយកមកពិចារណាបន្ថែមក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី២ ដូចខាងក្រោមនេះ៖

***ភាពខ្លាំង***

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយពីគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី១ និងបានទទួលស្គាល់ជាផែនទីបង្ហាញផ្លូវក្នុងវិស័យពិការភាពសម្រាប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល និងបងប្អូនមានពិការភាពយកទៅអនុវត្តជាផែនការសកម្មភាព ដើម្បីផ្តល់ផលប្រយោជន៍និងលើកកម្ពស់គុណភាពជីវិតព្រមទាំងសុខុមាលភាពរបស់ជនមានពិការភាព។

ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យពិការភាពមួយនេះ ត្រូវបានតាក់តែងឡើងឲ្យមានសង្គតិភាពជាមួយបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិពាក់ព័ន្ធ ព្រមទាំងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់ **"ធ្វើឲ្យសិទ្ធិក្លាយជាការពិត"** សម្រាប់ជនមានពិការភាពប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលបានធ្វើការត្រួតពិនិត្យវាយតម្លៃក្នុងអំឡុងពេលនៃការអនុវត្តពាក់កណ្តាលអាណត្តិ និងបានធ្វើការវាស់វែងការអនុវត្តនៅចុងអាណត្តិ ដោយមានការចូលរួមពីគ្រប់ដៃគូអនុវត្តនិងអ្នកអង្កេតការណ៍។

***ភាពខ្សោយ***

ទោះបីជាយ៉ាងនេះក្តី ការយល់ដឹងអំពីផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព អាចនៅមានកម្រិតនៅឡើយពីសំណាក់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព និងអង្គការមិនមែនរដ្ឋាភិបាល។ មានមូលហេតុចម្បងៗដែលធ្វើឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីពិការភាព

២០១៤ដល់២០១៨កន្លងមកមិនទទួលបានលទ្ធផល១០០% ដោយសារកង្វះខាតធនធានថវិកាសម្រាប់ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះតាមវិស័យ។ កង្វះខាតធនធានសម្ភារៈនិងបច្ចេកវិទ្យាដែលអាចជួយពន្លឿនប្រសិទ្ធភាពការងារ ការប្រមូលនិងគ្រប់គ្រងទិន្នន័យ ការតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពការងារ ការឆ្លើយតបនឹងតម្រូវការ ជនមានពិការភាព។ ធនធានមនុស្សនិងសមត្ថភាព និងការសហការពីគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត ភាពសកម្មនៃស្ថាប័នដែលត្រូវទទួលខុសត្រូវក៏នៅមានភាពខ្វះចន្លោះជាដើម។

*កាលានុវត្តភាព*

ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់វិស័យពិការភាពជាកិច្ចការអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងៗ។ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួងស្ថាប័នចំនួន២២ និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានីខេត្តបានចំនួន២៥ ដែលជាយន្តការមួយមានសក្តានុពលក្នុងការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ឲ្យមានប្រសិទ្ធភាពតាមរយៈការជួយផ្តល់ជំនួយបច្ចេកទេសពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ។ ក្រៅពីនេះ មូលនិធិជនពិការ នាយកដ្ឋានសុខុមាលភាពជនពិការ និងរដ្ឋបាលសិទ្ធិជនពិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាកាតាលីករធ្វើឲ្យមានជោគជ័យភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិខាងលើនេះ។

រាជរដ្ឋាភិបាលកម្ពុជានឹងនិយ័តថវិការដ្ឋដើម្បីជួយគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិខាងលើតាមរយៈការផ្តល់ថវិកាដល់ក្រសួង ស្ថាប័ន ដើម្បីប្រែក្លាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ទៅជាផែនការសកម្មភាពយកទៅអនុវត្តឲ្យបានជោគជ័យ។

ទន្ទឹមនឹងនេះ ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិនឹងផ្តល់ជំនួយបច្ចេកទេសនិងថវិកា ក្នុងការចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រជាតិខាងលើនេះឲ្យទទួលបានលទ្ធផលល្អដល់ក្រុមគោលដៅ ដែលជាជនមានពិការភាពគ្រប់ប្រភេទទទួលបាននូវអត្ថប្រយោជន៍ពីផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី២ បានរៀបចំឡើងដោយស្របគ្នាជាមួយនឹងអាណត្តិរាជរដ្ឋាភិបាលនិងមានសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ និងលិខិតុបករណ៍ជាតិនិងអន្តរជាតិ។

*ការគំរាមកំហែង*

ផលប៉ះពាល់ដោយគ្រោះថ្នាក់ចរាចរណ៍ មីន សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម គ្រោះមហន្តរាយដោយទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ជំងឺមិនឆ្លង និងគ្រោះថ្នាក់ផ្សេងៗទៀត រួមទាំងសមត្ថភាពនៅមានកម្រិតសម្រាប់ឆ្លើយតបទៅនឹងបញ្ហាពិការភាពគឺជាមូលហេតុដែលអាចធ្វើឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះមិនអាចសម្រេចបាន១០០%។ ការយល់ដឹងអំពីសារៈសំខាន់នៃវិស័យពិការភាព និងចំណេះដឹងរបស់ជនមានពិការភាពខ្លួនឯងផ្ទាល់ក៏ជាកត្តាស្មុគស្មាញក្នុងការលើកកម្ពស់សិទ្ធិជនមានពិការភាព។

*ស្ថាប័នសម្របសម្រួលការងារពិការភាព*

**ក្រុមប្រឹក្សាសកម្មភាពជនពិការ** គឺជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាពតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដោយមានភារកិច្ចក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ

ជាតិនិងផែនការសកម្មភាពទាក់ទងនឹងពិការភាព និងមានភារកិច្ចជំរុញការអនុវត្ត តាមដាន វាយតម្លៃ ការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព។

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស និងមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន ព្រមទាំងមានអនុប្រធានចំនួន៦រូប និងមានសមាជិកមកពីតាមបណ្តាក្រសួង ស្ថាប័ន តំណាងអង្គការជនមានពិការភាពដែលជាជនមានពិការភាព តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យពិការភាព តំណាងនិយោជក និងអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្តនីមួយៗសរុបចំនួនទាំងអស់៥៨រូប។

**ក្រុមប្រឹក្សាសកម្មភាពជនពិការ** មានតួនាទីនិងភារកិច្ចក្នុងការផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងស្តារលទ្ធភាពពលកម្ម ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិនិងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធនឹងពិការភាព និងស្តារលទ្ធភាពពលកម្ម ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម លើកសំណើកែសម្រួលនឹងបញ្ហាពិការភាព តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ កៀរគរប្រភពធនធានទាំងក្នុងទាំងក្រៅប្រទេស រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត រៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការរៀបចំរបាយការណ៍ស្តីពីស្ថានភាពជនមានពិការភាពជូនរាជរដ្ឋាភិបាល និងបំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលមានរចនាសម្ព័ន្ធគ្រប់គ្រងចំនួន៥(ប្រាំ)ផ្នែក។

ក្រុមប្រឹក្សាសកម្មភាពជនពិការ នៅថ្នាក់រាជធានី ខេត្ត និងក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័នមានតួនាទីនិងភារកិច្ចសម្រេចឲ្យបាននូវតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការដូចបានចែងនៅផ្នែកខាងលើ។

**មូលនិធិជនពិការ** គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដោយមានភារកិច្ចក្នុងការផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនមានពិការភាព និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនមានពិការភាពដូចជា ផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារឲ្យធ្វើ។

មូលនិធិជនពិការក៏ជាគ្រឹះស្ថានលើកកម្ពស់និងបង្កើនសុខុមាលភាពរបស់ជនមានពិការភាព ជាពិសេសជនមានពិការភាពក្រីក្រ និងយោធិនមានពិការភាពដែលមិនបានទទួលសេវាស្តារលទ្ធភាពពលកម្ម គ្រួសារជនមានពិការភាពក្រីក្រដែលពឹងផ្អែកលើជនមានពិការភាពក្នុងជីវភាពរស់នៅ និងយោធិនមានពិការភាពដែលបានទទួលសេវាស្តារលទ្ធភាពពលកម្មឬជនមានពិការភាពដែលមានជំនាញតែពុំទាន់ទទួលបានការងារធ្វើ។

មូលនិធិជនពិការមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ប្រាក់កម្ចីសម្រាប់ការសម្របសម្រួលសមស្រប។

**រដ្ឋបាលសិទ្ធិជនពិការ** បច្ចុប្បន្នគឺជាអង្គភាពចំណុះនាយកដ្ឋានសុខុមាលភាពជនពិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានភារកិច្ចក្នុងការផ្សព្វផ្សាយគោលនយោបាយ ច្បាប់ជាតិ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្របសម្រួលលើកទឹកចិត្តដល់ជនមានពិការភាព ក្រសួង ស្ថាប័ន និយោជកនិងគ្រឹះស្ថាននានាឲ្យអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ធ្វើអធិការកិច្ច ចំពោះ ក្រសួង ស្ថាប័ន និងនីតិបុគ្គលស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនមានពិការភាព ក្រសួងស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជន ព្រមទាំងអង្គការពាក់ព័ន្ធនានាផ្តល់សេវាសម្របសម្រួល ផ្សះផ្សារ ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតឡើងក្រោមក្របខ័ណ្ឌនៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងចាត់វិធានការ ពិន័យអន្តរការណ៍តាមមាត្រា៥៤នៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការចំពោះក្រសួង ស្ថាប័ន គ្រឹះស្ថាន សាធារណៈ និងគ្រឹះស្ថានឯកជន ដែលខកខានមិនបានបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។

## ៥.៣- ទិសដៅជាយុទ្ធសាស្ត្រ

### ទិសដៅជាយុទ្ធសាស្ត្រទី១ បង្កើនការងារនិងសន្តិសុខសេដ្ឋកិច្ច

### គោលដៅទី១.១- កាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់កំណើនការងារសមស្រប

**យុទ្ធសាស្ត្រ៖**

១.១.១- បង្កើនការផ្សព្វផ្សាយព័ត៌មានឬប្រព័ន្ធស្វែងរកការងារឲ្យបានទូលំទូលាយដល់ជនមានពិការភាព។

១.១.២- បង្កើនការយល់ដឹងអំពីបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកំណត់អត្រានិងបែបបទជ្រើសរើសជនមានពិការភាពចូលបម្រើការងារជាមួយអ្នកជាប់កាតព្វកិច្ច។

១.១.៣- កសាងបទដ្ឋានគតិយុត្តដើម្បីផ្ទៀងផ្ទាត់សមត្ថភាពនិងការងាររបស់ជនមានពិការភាពដែលអាចធ្វើបាន និងផ្តល់ការសម្របសម្រួលរកការងារដល់ជនមានពិការភាពដែលមានលក្ខណៈសម្បត្តិនិងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង។

១.១.៤- ពង្រឹងយន្តការសម្របសម្រួលដោះស្រាយពាក្យបណ្តឹង ទប់ស្កាត់ដល់ការរើសអើងជនមានពិការភាពចូលបម្រើការងារ បន្តការងារ ដើម្បីធានាឱកាស ប្រាក់កម្រៃ លក្ខខណ្ឌការងារ សុវត្ថិភាព និងផាសុកភាពស្មើគ្នា រួមទាំងកិច្ចការពារពីការយាយី និងការសងដំងឺចិត្ត។

១.១.៥- លើកទឹកចិត្តតាមគ្រប់មធ្យោបាយដល់និយោជកគំរូដែលជ្រើសរើសជនមានពិការភាពបានគ្រប់ឬលើសអត្រាកំណត់។

១.១.៦- ផ្តល់អាទិភាពឲ្យជនមានពិការភាពបានចូលបំពេញការងារជាអ្នកស្ម័គ្រចិត្ត មន្ត្រីជាប់កិច្ចសន្យា កម្មសិក្សាការី ឬកូនជាងដើម្បីទទួលបានបទពិសោធនៅក្នុងទីផ្សារ។

១.១.៧- កសាងបទដ្ឋានគតិយុត្តដើម្បីធានាការរក្សាក្របខ័ណ្ឌការងារដល់មន្ត្រីឬនិយោជិតដែលរងគ្រោះបណ្តាលឲ្យមានពិការភាពបន្តបម្រើការងារតាមស្ថានភាពនិងលទ្ធភាពជាក់ស្តែងក្រោយពេលទទួលបានការស្តារលទ្ធភាពពលកម្ម។

១.១.៨- អនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដើម្បីឲ្យកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. ទទួលបានការការពារពីផ្នែកហានិភ័យការងារ។

១.១.៩- បង្កើនការយល់ដឹងអំពីសិទ្ធិ សមត្ថភាព និងសក្ដានុពលរបស់ជនមានពិការភាពក្នុងចំណោមនិយោជក សហជីព ព្រមទាំងពង្រឹងសមត្ថភាពបន្ថែមដល់និយោជិតមានពិការភាព តាមរយៈកម្មវិធីស្ពានចម្លងបន្តជំនាញ។

១.១.១០- ផ្ដល់ឱកាសទទួលបានការងារជាថ្មីឬប្រកបមុខរបរផ្ទាល់ខ្លួនរបស់ជនមានពិការភាព តាមរយៈការអនុវត្តបុននីតិសម្បទា។

១.១.១១- ធានាឲ្យមានការសម្របសម្រួលសមស្របដល់ជនមានពិការភាពនៅក្នុងកន្លែងធ្វើការ។

១.១.១២- ធានាជនមានពិការភាពមិនត្រូវធ្លាក់ទៅក្នុងទាសភាពឬខ្ញុំបម្រើគេ ហើយត្រូវបានការពារពីការធ្វើពលកម្មដោយបង្ខំឬដោយមិនអាចប្រកែកបាន។

**គោលដៅទី១.២- ពង្រឹងពង្រីកអាជីពនិងមុខរបរដើម្បីបង្កើនជីវភាពរស់នៅបានសមរម្យ**

**យុទ្ធសាស្ត្រ៖**

១.២.១- វិភាគប្រភេទអាជីវកម្មនិងមុខរបរដែលសមស្របសម្រាប់ជនមានពិការភាពនិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដើម្បីធានានិរន្តរភាពមុខរបរនិងអាជីវកម្ម។

១.២.២- បង្កើនការយល់ដឹងអំពីឱកាសក្លាយជាសហគ្រិនភាព ក្នុងការបង្កើតសាជីវកម្មនិងការចាប់ផ្ដើមធ្វើធុរកិច្ចដោយខ្លួនឯង។

១.២.៣- តម្រង់ទិសក្នុងការបង្កើតមុខរបរសមស្របសម្រាប់ជនមានពិការភាព តាមរយៈការស្រាវជ្រាវអំពីតម្រូវការមូលដ្ឋាននិងការពិគ្រោះយោបល់។

១.២.៤- ផ្ដល់ជំនាញសហគ្រិនភាពដល់ជនមានពិការភាពនិងក្រុមគ្រួសារក្រីក្រ ដែលមានជនមានពិការភាពក្នុងបន្ទុកដើម្បីបង្កើត ពង្រឹង និងពង្រីកមុខរបរសមស្រប។

១.២.៥- លើកកម្ពស់សមត្ថភាពជំនាញគ្រប់គ្រងហិរញ្ញវត្ថុដល់ជនមានពិការភាពដើម្បីធានានិរន្តរភាពការប្រកបមុខរបរ។

១.២.៦- ស្វែងរកការគាំទ្រជាមួយស្ថាប័នផ្ដល់ឥណទានដែលផ្ដល់ការប្រាក់ទាបឬគ្មានការប្រាក់ និងផ្ដល់សម្បទានសម្រាប់ប្រកបមុខរបរឬតាមរយៈការកាត់បន្ថយពន្ធនិងការផ្ដល់អាទិភាពផ្សេងទៀតដល់ជនមានពិការភាពដើម្បីបង្កើតមុខរបរផ្ទាល់ខ្លួនដូចជាកសិមុខរបរ មុខរបរខ្នាតតូច ខ្នាតមធ្យម ខ្នាតធំជាលក្ខណៈឯកត្តជនឬសមូហភាព។

១.២.៧- លើកទឹកចិត្តដល់ជនមានពិការភាពប្រើប្រាស់ទីផ្សារក្នុងនាមជាអតិថិជន អ្នកផ្គត់ផ្គង់ និងសហគ្រិនភាព តាមរយៈគោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ដោយបន្សីការផ្លាស់ប្ដូរផ្នត់គំនិតទៅក្នុងការអនុវត្តជាក់ស្ដែងអំពីផលិតផលនិងសេវាកម្មរបស់ជនមានពិការភាព។

១.២.៨- ពង្រឹងនិងពង្រីកបណ្ដាញក្រុមជួយខ្លួនឯងរបស់ជនមានពិការភាព ដើម្បីលើកកម្ពស់ជីវភាពរស់នៅតាមរយៈសកម្មភាពបង្កើនប្រាក់ចំណូលនៅក្នុងសហគមន៍។

១.២.៩- បន្តការគាំទ្រផ្នែកធនធានបច្ចេកទេសនិងថវិកា ដើម្បីអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងផលិតផលឬសេវាតាមគ្រប់មធ្យោបាយដល់សហគ្រិនភាពមានពិការភាព។

**គោលដៅទី១.៣- ធានាការទទួលបានប្រព័ន្ធជំនួយសង្គម**

**យុទ្ធសាស្ត្រ៖**

១.៣.១- ជំរុញការកំណត់អត្តសញ្ញាណដើម្បីទទួលបានសេវាកម្មនិងផលប្រយោជន៍សង្គមផ្សេងៗទៀត រួមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនមានពិការភាព ដែលជាសមាជិកគ្រួសារក្រីក្រ មានបណ្ណសមធម៌។

១.៣.២- ជំរុញការធ្វើវិភាគទានពីវិស័យឯកជន ដោយលើកទឹកចិត្តឲ្យចូលរួមបង់វិភាគទានសម្រាប់ទ្រទ្រង់មូលនិធិជនពិការ តាមរយៈការដាក់ចេញគោលនយោបាយលើកទឹកចិត្តផ្សេងៗ ដូចជាការបង់វិភាគទានចូលមូលនិធិជនពិការ ត្រូវបានទទួលស្គាល់ជាចំណាយមុនបង់ពន្ធ ឬការលើកទឹកចិត្តផ្សេងៗទៀត។

១.៣.៣- លើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលមានលទ្ធភាព ចូលរួមបង់វិភាគទានក្នុងយុទ្ធនាការ "បួនពាន់រៀលសម្រាប់ជួយជនមានពិការភាព"រៀងរាល់ឆ្នាំនៅទិវាជនមានពិការភាព សម្រាប់ទ្រទ្រង់កម្មវិធីគាំពារជនមានពិការភាព។

១.៣.៤- ធានាដល់ជនមានពិការភាពឲ្យទទួលបានសេវាកម្មទឹកស្អាត គ្រឿងឧបករណ៍ និងជំនួយផ្សេងៗសមស្របដែលមានតម្លៃសមរម្យ សម្រាប់បម្រើសេចក្តីត្រូវការពាក់ព័ន្ធនឹងពិការភាព។

១.៣.៥- ធានាដល់ជនមានពិការភាពនិងក្រុមគ្រួសាររបស់គេដែលកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ ឲ្យទទួលបាននូវជំនួយឧបត្ថម្ភពីរដ្ឋតាមរយៈខ្ទង់ចំណាយលើផ្នែកពិការភាព រួមទាំងការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សាជំនួយហិរញ្ញវត្ថុ និងការថែទាំគ្រប់គ្រាន់ក្នុងអំឡុងពេលសម្រាក។

១.៣.៦- ពង្រីកការផ្តល់ផ្ទះសំបែងជាសាធារណៈដល់ជនមានពិការភាពតាមការវាយតម្លៃលក្ខខណ្ឌបានកំណត់។

**ទិសដៅជាយុទ្ធសាស្ត្រទី២ បង្កើនលទ្ធភាពទទួលសេវាសុខភាពនិងស្តារលទ្ធភាពពលកម្ម**

**គោលដៅទី២.១- បង្កើនការផ្តល់សេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ដោយគ្មានការរើសអើង ប្រកបដោយគុណភាពនិងចីរភាព**

**យុទ្ធសាស្ត្រ៖**

២.១.១- ពង្រីកអត្ថប្រយោជន៍និងលក្ខខណ្ឌនៃប្រព័ន្ធជំនួយសង្គមនិងប្រព័ន្ធសន្តិសុខសង្គម ដោយផ្អែកលើលទ្ធភាពទ្រទ្រង់ថវិកាជាតិ ដើម្បីធានាថាជនមានពិការភាពទទួលសេវាថែទាំសុខភាព ប្រកបដោយគុណភាពនិងឥតបង់ប្រាក់។

២.១.២- ពង្រីកវិសាលភាពនៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម(ប.ស.ស.)ដោយដាក់បញ្ចូលជនមានពិការភាពជាបន្ទុកចំណាយរបស់រដ្ឋ។

២.១.៣- ពង្រីកកម្មវិធីមូលនិធិសមធម៌ ដើម្បីបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងចំណោមជនមានពិការភាព។

២.១.៤- លើកកម្ពស់ការយល់ដឹងអំពីពិការភាពបឋមដល់អ្នកផ្តល់សេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ដើម្បីបន្ថយនិងបង្ការពិការភាពឲ្យបានជាអប្បបរមាក្នុងចំណោមកុមារនិងមនុស្សចាស់។

២.១.៥- ពង្រឹងការអនុវត្តសេចក្តីណែនាំគ្លីនិកនិងប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមានិងសំណុំសកម្មភាពបង្គ្រប់ដើម្បីធានាដល់ការផ្តល់វិជ្ជាជីវៈថែទាំសុខភាពដល់ជនមានពិការភាពឲ្យមានគុណភាពដូចគ្នានឹងការថែទាំអ្នកដទៃ។

២.១.៦- ដាក់បញ្ចូលការធានាដល់ការផ្តល់សេវាធានារ៉ាប់រងសុខភាពនិងការធានារ៉ាប់រងជីវិតទៅក្នុងលិខិតបទដ្ឋានគតិយុត្តនៃវិស័យពាក់ព័ន្ធ។

២.១.៧- បង្កើនកម្រិតជំនាញវិជ្ជាជីវៈសុខភាពនិងនិយាមក្រមសីលធម៌ដល់មន្ត្រីនៅតាមមូលដ្ឋានសុខាភិបាល ដើម្បីផ្តល់សេវាសុខភាពដល់ជនមានពិការភាពប្រកបដោយគុណភាពទៅតាមប្រភេទនិងកម្រិតពិការភាព។

២.១.៨- បង្កើនកម្មវិធីបង្ការពិការភាពដល់ពលរដ្ឋគ្រប់រូប តាមរយៈការថែទាំសុខភាពក្នុងពេលមានគភ៌ ការតាមដាន និងការវិនិច្ឆ័យរោគដែលនាំឲ្យមានពិការភាពទាន់ពេលវេលា ការផ្តល់ថ្នាំបង្ការជំងឺដែលនាំឲ្យមានពិការភាព ការផ្តល់អាហារទ្រទ្រង់រាងកាយ ការអប់រំអំពីមូលហេតុដែលនាំឲ្យមានពិការភាព ការព្យាបាលតាមវិធីវេជ្ជសាស្ត្រ និងការអប់រំកាយសម្បទាឡើងវិញឲ្យទាន់ពេលវេលា។

២.១.៩- បង្កើនលទ្ធភាពទទួលបានជំនួយផ្នែកបុគ្គល តាមរយៈការពង្រឹងការគ្រប់ដណ្តប់នៃក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

**គោលដៅទី២.២- ផ្តល់សេវាស្តារលទ្ធភាពពលកម្មឲ្យបានសមស្រប**

**យុទ្ធសាស្ត្រ៖**

២.២.១- ធ្វើបច្ចុប្បន្នកម្មនិងពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីការងារស្តារលទ្ធភាពពលកម្មកាយសម្បទានៅកម្ពុជា ដើម្បីធានាដល់ការផ្តល់សេវាប្រកបដោយគុណភាព។

២.២.២- ធានាការប្រើប្រាស់ឧបករណ៍វាយតម្លៃដំណាក់កាលដំបូង ដោយផ្អែកលើការវាយតម្លៃពហុជំនាញលើតម្រូវការនិងចំណុចខ្លាំងរបស់ជនមានពិការភាពម្នាក់ៗ។

២.២.៣- បង្កើនចំនួននិងពង្រឹងអ្នកជំនាញផ្នែកសុខភាព និងស្តារលទ្ធភាពពលកម្ម តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសបឋម បណ្តុះបណ្តាលបន្ត និងជំរុញលទ្ធភាពចំណេះដឹងនៃការប្រើប្រាស់ឧបករណ៍ជំនួយ និងបញ្ចូលផ្នែកនេះ នៅគ្រប់មន្ទីរពេទ្យ មណ្ឌលសុខភាពមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងគ្លីនិកឯកជន។

២.២.៤- ពង្រឹងការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា ទាក់ទងនឹងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម រួមទាំងការធ្វើទំនើបកម្មឧបករណ៍ជំនួយ។

២.២.៥- ពង្រឹងនិងពង្រីកសេវាកម្មនិងកម្មវិធីស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពនិងសមធម៌តាមរយៈការពង្រឹងយន្តការអភិបាលកិច្ច យន្តការបញ្ជូន និងយន្តការផ្តល់ហិរញ្ញប្បទាន។

២.២.៦- បង្កើនការចូលរួមរបស់ក្រុមគ្រួសារ សហគមន៍ និងអ្នកស្ម័គ្រចិត្ត មិត្តជួយមិត្ត ក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មដល់ជនមានពិការភាព តាមរយៈការអប់រំ ផ្សព្វផ្សាយ និងបំប៉ន។

២.២.៧- បង្កើនចំណេះដឹងអំពីការប្រើប្រាស់ និងថែទាំឧបករណ៍ជំនួយសម្រាប់ជនមានពិការភាពដើម្បីធានាដល់ការប្រើប្រាស់ឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព។

២.២.៨- បង្កើនការផលិតឧបករណ៍ជំនួយសម្រាប់ជនមានពិការភាព ដើម្បីធានាដល់ការប្រើប្រាស់បានគ្រប់គ្រាន់។

២.២.៩- ប៉ាន់ប្រមាណការបម្រុងថវិកាជាតិសម្រាប់វិស័យស្តារលទ្ធភាពពលកម្ម ដើម្បីធានានិរន្តរភាពនៃមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម។

២.២.១០- ធានានិរន្តរភាពធនធានមន្ត្រីជំនាញផ្នែកស្តារលទ្ធភាពពលកម្ម ដើម្បីបន្តការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ។

២.២.១១- ពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ និងផ្សព្វផ្សាយពីសេវាស្តារលទ្ធភាពពលកម្មដល់មន្ត្រីមូលដ្ឋាននិងសហគមន៍។

**ទិសដៅជាយុទ្ធសាស្ត្រទី៣ លទ្ធភាពទទួលបានការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

**គោលដៅទី៣.១- លើកកម្ពស់ការអប់រំដល់ជនមានពិការភាពប្រកបដោយគុណភាព បរិយាបន្ន សមភាព សមធម៌ និងពេញមួយជីវិត**

**យុទ្ធសាស្ត្រ៖**

៣.១.១- លើកកម្ពស់ការយល់ដឹងពីសក្តានុពលនិងសារៈសំខាន់នៃការអប់រំរបស់ជនមានពិការភាពដល់ក្រុមគ្រួសារ សហគមន៍ និងក្រុមការងារអប់រំ។

៣.១.២- ធ្វើផែនទីសិក្សានិងកំណត់អត្តសញ្ញាណកម្មជនមានពិការភាពដែលមានតម្រូវការពិសេសក្នុងការចុះឈ្មោះចូលរៀន ទទួលអាហារូបករណ៍ និងចូលរួមប្រឡង។

៣.១.៣- បង្កើនការផ្តល់ក្របខ័ណ្ឌដល់គ្រូបង្រៀន រួមទាំងគ្រូដែលមានពិការភាពដែលមានសមត្ថភាពបង្រៀនភាសាសញ្ញា អក្សរប្រៃយ៍(អក្សរស្ទាប) និងកម្មវិធីសិក្សាអប់រំពិសេស សម្រាប់គ្រប់កម្រិតសិក្សា។

៣.១.៤- បង្កើតនិងបង្កើនសម្ភារៈសិក្សាមានស្តង់ដាដើម្បីឲ្យជនមានពិការភាពអាចប្រើប្រាស់បានសម្រាប់ការសិក្សាស្រាវជ្រាវគ្រប់កម្រិត។

៣.១.៥- ពង្រឹងយន្តការសម្របសម្រួលដើម្បីជំរុញការអនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នធានាដល់កុមារមានពិការភាពទទួលបានការសិក្សារៀនសូត្រដោយឥតគិតថ្លៃ។

៣.១.៦- កសាងបទដ្ឋានគតិយុត្តដើម្បីធានាការដាក់បញ្ចូលការអប់រំបរិយាបន្ននិងអប់រំពិសេសទៅក្នុងគ្រឹះស្ថានអប់រំឯកជន។

៣.១.៧- ជំរុញឲ្យមានការដាក់បញ្ចូលកម្មវិធីលេងកម្សាន្ត ការលម្ហែ និងការសម្តែងដើម្បីឲ្យសិស្សមានពិការភាពបានចូលរួមពេញលេញដូចសិស្សដទៃ។

**គោលដៅ៣.២- បណ្តុះបណ្តាលជំនាញដល់ជនមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៣.២.១- លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់ជនមានពិការភាព។

៣.២.២- ធ្វើទំនើបកម្មកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងបង្កិតកម្មវិធីឲ្យកៀកជិតជនមានពិការភាព ស្របតាមតម្រូវការទីផ្សារការងារ។

៣.២.៣- ជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយបរិយាបន្ន តាមរយៈយន្តការសម្របសម្រួលការអនុវត្តក្របខ័ណ្ឌគតិយុត្ត និងការគាំទ្រផ្នែកបច្ចេកទេស។

៣.២.៤- ជំរុញការបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈជនមានពិការភាព ស្របទៅតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

៣.២.៥- ជំរុញការវិភាជកញ្ចប់ថវិកាតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឧបត្ថម្ភដល់ជនមានពិការភាពទទួលបានការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣.២.៦- បង្កើនលទ្ធភាពឲ្យជនមានពិការភាពបានចូលបំពេញការងារស្ម័គ្រចិត្ត ដើម្បីទទួលបានបទពិសោធនៅក្នុងទីផ្សារការងារសេរី។

៣.២.៧- លើកទឹកចិត្តនិងគាំទ្រដល់និយោជក គ្រឹះស្ថានសិក្សា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលបានផ្តល់ឱកាសដល់ជនមានពិការភាពឬក្រុមគ្រួសារទទួលបានការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំនាញ។

៣.២.៨- កសាងសមត្ថភាពអំពីជំនាញទំនាក់ទំនង តាមរយៈការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការកសាងទំនុកចិត្ត និងការកំណត់នូវទិសដៅមុខរបរ។

**ទិសដៅជាយុទ្ធសាស្ត្រទី៤ ការបង្កលក្ខណៈងាយស្រួល**

**គោលដៅទី៤.១- កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងឧបករណ៍ផ្សេងៗទៀតសម្រាប់ជនមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៤.១.១- លើកកម្ពស់និងផ្សព្វផ្សាយការយល់ដឹងអំពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពដល់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

៤.១.២- ពង្រឹងការកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល សម្រាប់ជនមានពិការភាពដែលរារាំងដល់ការចូលរួមពេញលេញរបស់ជនមានពិការភាព។

៤.១.៣- ពង្រឹងក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត យន្តការតាមដានត្រួតពិនិត្យ ដើម្បីជំរុញការអនុវត្តបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

៤.១.៤- ជំរុញការវិភាជថវិការដ្ឋដើម្បីគាំទ្រដល់ការសាងសង់និងកែសម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈរបស់រដ្ឋ។

៤.១.៥- ជំរុញក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធគ្រប់វិស័យចេញលិខិតជូនដំណឹងឲ្យមានការកែសម្រួលនិងរៀបចំបង្កលក្ខណៈងាយស្រួលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៤.១.៦- បង្កើនការដាក់ផ្លាកសញ្ញាចំណតអាទិភាពសម្រាប់ជនមានពិការភាព។

**គោលដៅទី៤.២- កែលម្អមធ្យោបាយដឹកជញ្ជូនសាធារណៈ រួមទាំងឧបករណ៍ផ្សេងៗទៀតសម្រាប់ជនមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៤.២.១- ជំរុញការកសាងបទដ្ឋានបច្ចេកទេសស្តីពីមធ្យោបាយដឹកជញ្ជូនសាធារណៈដែលបង្កលក្ខណៈងាយស្រួល សម្រាប់ជនមានពិការភាព។

៤.២.២- ជំរុញការកសាងប្រកាសអន្តរក្រសួងស្តីពីបណ្ណបើកបរ សមត្ថភាពបើកបរ និងប្រភេទយានយន្តសម្រាប់ជនមានពិការភាព។

៤.២.៣- លើកកម្ពស់និងផ្សព្វផ្សាយការយល់ដឹងអំពីបទដ្ឋានបច្ចេកទេសស្តីពីមធ្យោបាយដឹកជញ្ជូនសាធារណៈដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ដល់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

៤.២.៤- បង្កើនការយល់ដឹងដល់ភ្នាក់ងារ សាលារៀនបើកបរនៅទូទាំងប្រទេស អំពីសមត្ថភាពបើកបរយានយន្តពិសេសសម្រាប់តែជនមានពិការភាព។

៤.២.៥- ជំរុញឲ្យមានការទទួលយកជនមានពិការភាពចុះឈ្មោះរៀនបើកបរ និងទទួលបានបណ្ណបើកបរទៅតាមសមត្ថភាពនិងប្រភេទពិការភាព។

៤.២.៦- ជំរុញការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពទទួលបានសិទ្ធិក្នុងការប្រើប្រាស់យានយន្តនិងទទួលបានបណ្ណបើកបរ។

៤.២.៧- ជំរុញការកសាងលិខិតបទដ្ឋានគតិយុត្តស្ដីពីការចេញបណ្ណចំណតអាទិភាពសម្រាប់ជនមានពិការភាព។

**គោលដៅទី៤.៣- កែលម្អមធ្យោបាយទំនាក់ទំនង ចំណេះដឹង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងឧបករណ៍និងសេវាកម្មផ្សេងៗទៀតសម្រាប់ជនមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៤.៣.១- បង្កើនការប្រើប្រាស់ភាសាសញ្ញា អក្សររត់ អក្សរប្រៃយ៍(អក្សរស្ទាប) អក្សរពុម្ពធំ សំឡេងឲ្យបានទូលំទូលាយ ដើម្បីផ្ដល់ឱកាសទំនាក់ទំនង ការបញ្ចេញមតិយោបល់ និងទទួលបានព័ត៌មានសម្រាប់ជនមានពិការភាពគ្រប់ប្រភេទ។

៤.៣.២- ជំរុញការបំពាក់សំឡេងសញ្ញាចរាចរណ៍នៅតាមទីតាំងចរាចរណ៍សំខាន់ៗ។

៤.៣.៣- បង្កើតកម្មវិធីសុសវែរនិងឧបករណ៍ជំនួយទំនាក់ទំនងការនិយាយ ការអាន ការស្ដាប់ និងការមើលឲ្យបានទូលំទូលាយ ដែលជនមានពិការភាពគ្រប់គ្នាអាចប្រើប្រាស់បាន។

៤.៣.៤- ជំរុញការផលិតនិងបោះពុម្ពឯកសារឬព័ត៌មានជាទម្រង់ងាយស្រួលអានសម្រាប់ជនមានពិការភាព។

៤.៣.៥- ពង្រីកស្ថានីយផ្សាយនិងតំបន់គ្របដណ្ដប់នៃប្រព័ន្ធផ្សព្វផ្សាយ ដែលធ្វើប្រតិបត្តិការដោយជនមានពិការភាព។

**ទិសដៅជាយុទ្ធសាស្ត្រទី៥- ការចូលរួមដោយសមភាព**

**គោលដៅទី៥.១- លើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងជីវភាពសាធារណៈ**

**យុទ្ធសាស្ត្រ៖**

៥.១.១- ពង្រឹងសមត្ថភាព លើកទឹកចិត្ត និងចងជាបណ្ដាញដល់ជនមានពិការភាព ដើម្បីបានចូលរួមក្នុងអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមពាក់ព័ន្ធនឹងជីវភាពសាធារណៈរបស់ប្រទេសក្នុងសកម្មភាពរដ្ឋបាលនានា។

៥.១.២- គាំទ្រដល់ការបង្កើតនិងសម្របសម្រួលការទទួលស្គាល់អង្គការ សមាគមជនពិការនានាដើម្បីធ្វើជាអ្នកតំណាងជនមានពិការភាពនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅលើឆាកអន្តរជាតិ។

៥.១.៣- ជំរុញកាតព្វកិច្ចរបស់ក្រសួងស្ថាប័ននិងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីផ្ដល់សិទ្ធិដល់ជនមានពិការភាព ក្នុងការសម្រេចចិត្តនៅគ្រប់សកម្មភាពគ្រួសារនិងអភិវឌ្ឍន៍សង្គម។

**គោលដៅទី៥.២- លើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងជីវភាពនយោបាយ**

**យុទ្ធសាស្ត្រ៖**

៥.២.១- ជំរុញការដាក់បញ្ចូលពិការភាពទៅក្នុងគោលនយោបាយរបស់គណបក្សនយោបាយនិងនីតិវិធីប្រកបដោយប្រសិទ្ធភាពនិងពេញលេញ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃក្នុងការបោះឆ្នោតនិងឈរឈ្មោះឲ្យគេបោះឆ្នោត។

៥.២.២- លើកកម្ពស់ការយល់ដឹងដល់គ្រប់ភាគីនយោបាយ អាជ្ញាធរមូលដ្ឋានក្នុងការការពារសិទ្ធិរបស់ជនមានពិការភាពក្នុងការបោះឆ្នោតដោយសម្ងាត់ ការធ្វើប្រជាមតិសាធារណៈដោយគ្មានការបំភិតបំភ័យ ការឈរឈ្មោះបោះឆ្នោតចូលកាន់មុខតំណែង ការបំពេញគ្រប់មុខងារសាធារណៈ ឲ្យមានប្រសិទ្ធភាពនិងគ្រប់ជាន់ថ្នាក់។

៥.២.៣- ជំរុញការអនុវត្តច្បាប់ស្តីពីការបោះឆ្នោតនិងបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាដល់អ្នកបោះឆ្នោតដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត។

**គោលដៅទី៥.៣- ធានាដល់ការចូលរួមសកម្មភាពសង្គមរួមមានវប្បធម៌ សិល្បៈ សាសនា កីឡា ការសម្រាកលំហែ និងសកម្មភាពផ្សេងៗទៀត**

**យុទ្ធសាស្ត្រ៖**

៥.៣.១- កៀរគរប្រភពធនធានដើម្បីធានាដល់ការផ្គត់ផ្គង់សម្ភារៈផ្សេងៗក្នុងវិស័យសិល្បៈ វប្បធម៌ដល់ជនមានពិការភាពដែលមានលទ្ធភាពអាចប្រើប្រាស់បាន។

៥.៣.២- ចងក្រងជាក្រុមសិល្បៈ និងសម្របសម្រួលដើម្បីឲ្យជនមានពិការភាពអាចមានលទ្ធភាពចូលរួមកម្មវិធីសិល្បៈ វប្បធម៌ ក្នុងកម្មវិធីរបស់ទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗ។

៥.៣.៣- បង្កើតកម្មវិធីសិល្បៈនិងសកម្មភាពវប្បធម៌ ដើម្បីបង្ហាញសក្តានុពលដែលជនមានពិការភាពអាចចូលរួមសម្តែង បង្ហាញសមត្ថភាព និងប្រកួតប្រជែងបាន។

៥.៣.៤- អភិវឌ្ឍទេពកោសល្យខាងបញ្ញា សិល្បៈ គំនិតច្នៃប្រឌិត និងកីឡាជាសាធារណៈនៅគ្រប់កម្រិត។

៥.៣.៥- កសាងគោលនយោបាយបញ្ចុះតម្លៃលើមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ហូបចុក និងទីកន្លែងកម្សាន្ត សេវាផ្សេងៗ ដើម្បីបង្កឱកាសដល់ជនមានពិការភាពអាចមានលទ្ធភាពចាត់ចែងសកម្មភាពលំហែ ទេសចរណ៍ និងការកម្សាន្តដោយខ្លួនឯងបាន។

**ទិសដៅជាយុទ្ធសាស្ត្រទី៦- លទ្ធភាពទទួលបានសេវាយុត្តិធម៌និងសិទ្ធិសេរីភាព**

**គោលដៅ៦.១- លើកកម្ពស់ការផ្តល់សេវាយុត្តិធម៌ដល់ជនមានពិការភាពជាពិសេសដល់ស្ត្រីនិងក្មេងស្រីមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៦.១.១- ជំរុញការដាក់បញ្ចូលតម្រូវការផ្នែកច្បាប់សម្រាប់ជនមានពិការភាព ទៅក្នុងគោលនយោបាយជាតិទាក់ទងនឹងជំនួយផ្លូវច្បាប់។

៦.១.២- ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិស្តីពីពិការភាពដល់មន្ត្រីយុត្តិធម៌និងនគរបាលយុត្តិធម៌ ដើម្បីធានាការផ្តល់សេវាយុត្តិធម៌ដល់ជនមានពិការភាព ប្រកបដោយប្រសិទ្ធភាពនិងភាពពេញលេញ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

៦.១.៣- បន្តពង្រឹងយន្តការផ្តល់សេវាយុត្តិធម៌នៅគ្រប់កម្រិត តាមរយៈការបង្កើនកិច្ចសហការជាមួយក្រុមការងារធ្វើការផ្នែកពិការភាពក្នុងការផ្តល់សេវាយុត្តិធម៌ សេវាប្រឹក្សាយោបល់ និងសេវាសារវន្តផ្សេងទៀតដល់ជនរងគ្រោះ។

៦.១.៤- បង្កើនការយល់ដឹងអំពីសេវាជំនួយផ្លូវច្បាប់ដល់បណ្តាញជនមានពិការភាព ក្នុងការបញ្ជូនព័ត៌មានដល់ជនមានពិការភាព។

៦.១.៥- ស្វែងរកការគាំទ្រជាមួយយន្តការអន្តរក្រសួងនិងស្ថាប័នផ្តល់សេវាជំនួយផ្លូវច្បាប់ ដើម្បីបង្កើនកញ្ចប់ថវិកាជាតិសម្រាប់គាំទ្រដំណើរការរឿងក្តីរបស់ជនមានពិការភាព តាំងពីដំណាក់កាលដំបូងរហូតដល់សំណុំរឿងត្រូវបានបញ្ចប់។

៦.១.៦- ធានាឲ្យមានធនធានមនុស្សនិងថវិកា ដើម្បីជួយដល់ការសម្របសម្រួលសមស្របដល់ជនមានពិការភាព ក្នុងនីតិវិធីកាត់ក្តីគ្រប់ដំណាក់កាលឲ្យទទួលបានយុត្តិធម៌និងស្មើភាពដូចអ្នកដទៃ។

**គោលដៅ៦.២- លើកកម្ពស់កិច្ចការពារសេរីភាពនិងសន្តិសុខបុគ្គលរបស់ជនមានពិការភាព**

**យុទ្ធសាស្រ្ត៖**

៦.២.១- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ សេរីភាព និងសន្តិសុខបុគ្គលរបស់ជនមានពិការភាព តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ផែនការជាតិ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងពិការភាព។

៦.២.២- លើកកម្ពស់ការយល់ដឹងអំពីឥរិយាបថវិជ្ជមាន សេចក្តីថ្លៃថ្នូររបស់ជនមានពិការភាពក្នុងចំណោមជនមានពិការភាពខ្លួនឯង គ្រួសារ និងសហគមន៍។

៦.២.៣- បង្កើនការយល់ដឹងអំពីច្បាប់ជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងពិការភាព ដើម្បីការពារមិនឲ្យមានការដកហូតសេរីភាព សញ្ជាតិ ប្តូរសញ្ជាតិ និងដើរហើររបស់ជនមានពិការភាពដោយខុសច្បាប់។

៦.២.៤- ផ្តល់ការសម្របសម្រួលសមស្របដល់ជនមានពិការភាពក្នុងការធ្វើជាម្ចាស់លើអចលនទ្រព្យ ឬសន្តតិកម្ម ការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ។

៦.២.៥- បង្កើនការយល់ដឹងដល់អាណាព្យាបាលដែលជាសាច់ញាតិមានពិការភាព អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានការចុះបញ្ជីអត្រានុកូលដ្ឋាននិងអត្តសញ្ញាណបណ្ណ។

៦.២.៦- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ខ្លួននិងសេវាផ្លូវច្បាប់ដែលជនមានពិការភាពត្រូវទទួលបាន ដើម្បីបង្ការរាល់ទម្រង់នៃការកេងប្រវ័ញ្ច រំលោភបំពាន ទារុណកម្ម និងជួញដូរ។

៦.២.៧- ពង្រឹងគុណភាពសេវាឆ្លើយតបតម្រូវការជនរងគ្រោះដែលមានពិការភាព ទៅនឹងការគាំពារសុខភាព ផ្លូវកាយ ផ្លូវចិត្ត និងជំនួយសង្គម។

**ទិសដៅជាយុទ្ធសាស្ត្រទី៧- ធានាសមភាពយេនឌ័រ**

**គោលដៅទី៧.១- លើកកម្ពស់សមភាពយេនឌ័រនិងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីមានពិការភាព**

**យុទ្ធសាស្ត្រ៖**

៧.១.១- កសាងសមត្ថភាពស្ត្រីនិងក្មេងស្រីដែលមានពិការភាពអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការកេងប្រវ័ញ្ចផ្នែកជីវភាពសេដ្ឋកិច្ច ដើម្បីកសាងទំនុកចិត្តនិងកាត់បន្ថយការគិតអវិជ្ជមានចំពោះពិការភាពរបស់ខ្លួនឯង និងក្នុងចំណោមអ្នកផ្តល់សេវាជាមួយស្ត្រីនិងក្មេងស្រីមានពិការភាព។

៧.១.២- ពង្រឹងយន្តការការពារនិងទប់ស្កាត់អំពីអំពើហិង្សាទាក់ទងយេនឌ័រនិងការកេងប្រវ័ញ្ចផ្នែកជីវភាពសេដ្ឋកិច្ចលើស្ត្រីនិងក្មេងស្រីមានពិការភាព ក្នុងចំណោមអ្នកធ្វើការផ្ទាល់ជាមួយស្ត្រី។

៧.១.៣- បង្កើនកម្មវិធីបណ្តុះបណ្តាលដោយផ្តល់ឱកាសដល់ស្ត្រីនិងក្មេងស្រីមានពិការភាព អំពីភាពជាអ្នកដឹកនាំតាមវិស័យ ដើម្បីចូលរួមពេញលេញក្នុងភាពជាអ្នកដឹកនាំនិងទទួលបានមុខងារនៅគ្រប់កម្រិត។

៧.១.៤- លុបបំបាត់របាំងឧបសគ្គនៃការរើសអើងផ្នែកអាកប្បកិរិយា ទំនាក់ទំនង ការចូលរួម ដើម្បីធានាដល់ការបញ្ជ្រាបឲ្យមានតំណាងស្ត្រីមានពិការភាព នៅក្នុងស្ថាប័នធ្វើការសម្រេចចិត្តនៃរាជរដ្ឋាភិបាល។

៧.១.៥- ផ្តល់ការគាំទ្រដល់ការចងបណ្តាញការងារដើម្បីលើកទឹកចិត្តដល់ស្ត្រីមានពិការភាពទទួលបានការអភិវឌ្ឍ វឌ្ឍនភាព និងសិទ្ធិអំណាចឲ្យបានពេញលេញ។

៧.១.៦- បង្កើនការយល់ដឹងអំពីសុខភាពបន្តពូជសមស្របទៅតាមវ័យនិងលទ្ធភាពទទួលបានព័ត៌មានសេវាសុខភាពបន្តពូជសមស្រប ដើម្បីធានាដល់ការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើការកំណត់ចំនួនកូននិងចន្លោះពេលមានកូន។

៧.១.៧- ផ្សព្វផ្សាយកម្មវិធីកាត់បន្ថយភាពក្រីក្រ កម្មវិធីគាំពារសង្គម ការអភិវឌ្ឍ វឌ្ឍនភាព និងសេវាពហុវិស័យ ដើម្បីធានាផ្តោតលើតម្រូវការនិងអាទិភាពរបស់ស្ត្រី ក្មេងស្រី និងមនុស្សចាស់មានពិការភាព ដោយឈរលើមូលដ្ឋានសមភាព។

៧.១.៨- ពង្រឹងយន្តការសម្របសម្រួលរវាងវិស័យពិការភាពស្ត្រីនិងកុមារ ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រនារីរតនៈ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារកុមារ។

៧.១.៩- បង្កើនលទ្ធភាពទទួលបានចំណេះដឹងផ្នែកហិរញ្ញវត្ថុ មុខជំនាញ មុខរបរ សេវាឥណទានហិរញ្ញវត្ថុដល់ស្ត្រីមានពិការភាពតាមរយៈការផ្លាស់ប្តូរតវិធីយាបថអវិជ្ជមានរបស់ភ្នាក់ងារផ្តល់ឥណទាន។

**ទិសដៅជាយុទ្ធសាស្ត្រទី៨- កាត់បន្ថយហានិភ័យនិងផលប៉ះពាល់បង្កដោយគ្រោះមហន្តរាយ**

**គោលដៅ៨.១- ការត្រៀមបង្ការហានិភ័យគ្រោះមហន្តរាយ**

**យុទ្ធសាស្ត្រ៖**

៨.១.១- កសាងនិងអនុវត្តផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមវិស័យនីមួយៗ ដើម្បីបង្កើនកិច្ចការពារ អន្តរាគមន៍និងធានាសុវត្ថិភាពក្រុមងាយរងគ្រោះ ជាពិសេសជនមានពិការភាព។

៨.១.២- កសាងសមត្ថភាពអំពីពិការភាពដល់មន្ត្រីផ្តល់សេវានិងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានាថាជនមានពិការភាពជាកម្មវត្ថុអាទិភាពក្នុងការធ្វើអន្តរាគមន៍។

៨.១.៣- អភិវឌ្ឍចំណេះដឹងនិងវិធីសាស្ត្រថ្មីៗដល់ក្រុមគ្រួសារដែលមានសមាជិកមានពិការភាពនិងស្ថាប័នឆ្លើយតបគ្រោះមហន្តរាយគ្រប់កម្រិត ដើម្បីធានាថាជនមានពិការភាពត្រូវបានសង្គ្រោះប្រកបដោយសុវត្ថិភាព។

៨.១.៤- កំណត់ភូមិសាស្ត្រដែលងាយប្រឈមនឹងហានិភ័យគ្រោះមហន្តរាយ និងរៀបចំទីតាំងសុវត្ថិភាពដែលជនមានពិការភាពអាចប្រើប្រាស់បាន។

៨.១.៥- កំណត់អត្តសញ្ញាណនិងផែនទីស្នាក់នៅរបស់ជនមានពិការភាព ដើម្បីធានាថារាល់ព័ត៌មានអំពីគ្រោះហានិភ័យត្រូវបានដឹងមុន។

៨.១.៦- ត្រៀមបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារបរិភោគ ទីកន្លែង និងយន្តការជំនាញ ដោយផ្ដោតជាពិសេស លើជនមានពិការភាព។

**គោលដៅ៨.២- គ្រប់គ្រងស្ថានភាពនិងអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព**

**យុទ្ធសាស្ត្រ៖**

៨.២.១- ជំរុញការចូលរួមគ្រប់ស្ថាប័នជាតិ ក្រោមជាតិ សហគមន៍ ក្រុមគ្រួសារដើម្បីធ្វើអន្តរាគមន៍ដល់ជនមានពិការភាពទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

៨.២.២- ផ្ដល់ជំនួយមនុស្សធម៌ សង្គ្រោះបឋម និងសេវាបន្ទាន់ដល់ក្រុមកំពុងរងគ្រោះដោយគ្រោះមហន្តរាយ ប្រកបដោយបរិយាបន្ន។

៨.២.៣- បន្តតាមដានស្ថានភាពគ្រោះមហន្តរាយ ស្ថានភាពជនរងគ្រោះដែលជាជនមានពិការភាព រួចបន្តការគាំទ្រ ទាំងផ្លូវកាយ ផ្លូវចិត្ត និងអាហារ។

**គោលដៅទី៨.៣- ការស្ដារឡើងវិញក្រោយគ្រោះមហន្តរាយ**

**យុទ្ធសាស្ត្រ៖**

៨.៣.១- វាយតម្លៃផលប៉ះពាល់បន្ទាប់ពីគ្រោះមហន្តរាយនិងកំណត់សកម្មភាពអាទិភាពចំពោះជនមានពិការភាព ដើម្បីផ្ដល់សេវានិងជំនួយសមស្របតាមតម្រូវការ។

៨.៣.២- ស្ដារហេដ្ឋារចនាសម្ព័ន្ធខូចខាតឡើងវិញ ដើម្បីឲ្យជនមានពិការភាពអាចប្រើប្រាស់ប្រកបដោយភាពងាយស្រួលដូចដើម។

៨.៣.៣- ធ្វើសមាហរណកម្មជនមានពិការភាពទៅក្នុងសហគមន៍ដើមរបស់គាត់វិញ ដោយធានាជីវភាព សុខភាព មុខរបរ ការអប់រំ និងសេវាផ្សេងៗ។

**ទិសដៅជាយុទ្ធសាស្ត្រទី៩- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ និងធានាថាមានទិន្នន័យនិងស្ថិតិពិការភាពដែលអាចទុកចិត្ត និងប្រៀបធៀបបាន**

**គោលដៅ៩.១- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ**

**យុទ្ធសាស្ត្រ៖**

៩.១.១- ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដើម្បីផ្ដួចផ្ដើមនិងអនុវត្តកម្មវិធីនានាគាំទ្រការអនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងពិការភាព ដែលព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័នឬជាប្រទេសហត្ថលេខី។

៩.១.២- ពង្រឹងការផ្លាស់ប្ដូរបទពិសោធនិងការអនុវត្តល្អក្នុងកម្រិតជាតិនិងអន្តរជាតិ ដែលទាក់ទងនឹងជនមានពិការភាព។

៩.១.៣- បរិយាបន្នជនមានពិការភាពក្នុងកម្មវិធីអភិវឌ្ឍន៍នានានៃកិច្ចសហប្រតិបត្តិការ ក្នុងសហគមន៍ជាតិនិងអន្តរជាតិ ។

៩.១.៤- សម្របសម្រួលនិងគាំទ្រដល់ការកសាងសមត្ថភាពតាមរយៈការផ្លាស់ប្ដូរនិងការចែករំលែកព័ត៌មាន បទពិសោធ ការស្រាវជ្រាវ កម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេស វិទ្យាសាស្ត្រ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

៩.១.៥- កៀរគរធនធានថវិកានិងបច្ចេកទេសសមស្របនៅក្នុងកម្រិតជាតិនិងអន្តរជាតិ ដើម្បីអភិវឌ្ឍកម្មវិធីពិការភាព ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

៩.១.៦- ពង្រីកកិច្ចសហប្រតិបត្តិការ ការគាំទ្រ និងការចូលរួមពីបណ្តាក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធរួមទាំងវិស័យឯកជនទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធានាបរិយាបន្នពិការភាពនៅគ្រប់កម្មវិធីអភិវឌ្ឍន៍។

៩.១.៧- ផ្តល់របាយការណ៍ទៀងទាត់ស្តីពីការអនុវត្តលិខិតុបករណ៍ជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងពិការភាព ទៅតាមវិស័យនីមួយៗតាមទម្រង់ដែលបានកំណត់ ដើម្បីរួមចំណែកចងក្រងរបាយការណ៍ជាតិនិងអន្តរជាតិ។

៩.១.៨- ជំរុញការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការនិងសន្ធិសញ្ញាស្តីពីជនពិការក្នុងការពិបាកអានអក្សរបោះពុម្ព(សន្ធិសញ្ញាម៉ារ៉ាកេស)។

៩.១.៩- បំពេញកាតព្វកិច្ចជារដ្ឋភាគី តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងវេទិកាឬព្រឹត្តិការណ៍អន្តរជាតិ។

**គោលដៅ៩.២- ធានាថាមានទិន្នន័យនិងស្ថិតិពិការភាពដែលអាចទុកចិត្តនិងប្រៀបធៀបបាន**

**យុទ្ធសាស្ត្រ៖**

៩.២.១- បង្កើនការយល់ដឹងអំពីចំណាត់ថ្នាក់អន្តរជាតិនៃមុខងារអំពីពិការភាពនិងសុខភាព និងកម្រងសំណួរវ៉ាស៊ីនតោនដល់អ្នកពាក់ព័ន្ធនឹងការងារស្ថិតិ។

៩.២.២- ផលិតនិងផ្សព្វផ្សាយស្ថិតិជនមានពិការភាពដែលអាចទុកចិត្តបាននិងអាចប្រៀបធៀបបានជាលក្ខណៈអន្តរជាតិ ក្នុងទម្រង់ដែលអាចប្រើប្រាស់បានដោយជនមានពិការភាព។

៩.២.៣- ធ្វើការសិក្សា ស្រាវជ្រាវ និងអង្កេតថ្នាក់ជាតិស្តីពីពិការភាពក្នុងរយៈពេលទៀងទាត់។

៩.២.៤- ជំរុញឲ្យមានការកត់ត្រាព័ត៌មាននិងទិន្នន័យពិការភាពជាក់លាក់ទៅក្នុងការអនុវត្តសកម្មភាពគ្រប់វិស័យ។

៩.២.៥- បង្កើតនិងធ្វើប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាពថ្នាក់ជាតិ ដើម្បីញែកទិន្នន័យពិការភាពទៅតាមវ័យ ភេទ ស្ថានភាពសេដ្ឋកិច្ច ប្រភេទពិការភាព កម្រិតពិការភាពជាដើម ដែលព័ត៌មានទាំងនេះនឹងត្រូវបានប្រើក្នុងការកសាងផែនការជាតិនិងកម្មវិធីអភិវឌ្ឍន៍នានា។

## ៦- សកម្មភាពការងារ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣នេះ ផ្តល់ក្របខ័ណ្ឌធំទូលាយមួយ សម្រាប់អនុវត្តវិធានការឆ្លើយតបនឹងវិស័យពិការភាព។ ចាំបាច់ត្រូវរៀបចំផែនការសកម្មភាពនិងយន្តការពាក់ព័ន្ធនានាដូចជាយន្តការហិរញ្ញប្បទាន ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងក្របខ័ណ្ឌច្បាប់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីពិការភាពនេះនិងផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់ការកៀរគរធនធាន។

### ៦.១- ដំណាក់កាលសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ត្រូវអនុលោមតាមដំណាក់កាលដូចខាងក្រោម៖

- នៅក្នុងរយៈពេលខ្លី (២០១៩-២០២០) យន្តការចាត់ចែងស្ថាប័ននិងហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ត្រូវរៀបចំឡើងរួមផ្សំជាមួយក្របខ័ណ្ឌជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។ នៅក្នុងដំណាក់កាលនេះ ក្រសួងស្ថាប័នពាក់ព័ន្ធនីមួយៗត្រូវកសាងផែនការសកម្មភាពលម្អិតនិងចាត់អាទិភាព(២០១៩-២០២៣) ដែលរួមមានសូចនាករនិងសកម្មភាពជាក់លាក់មួយសម្រាប់ការគ្រប់គ្រងចំណេះដឹងនិងការសម្របសម្រួល។
- នៅក្នុងរយៈពេលមធ្យម (២០២០-២០២១) ដំណាក់កាលនេះនឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១ ជាមួយការពង្រីកសកម្មភាពដទៃទៀតដូចជា ការរៀបចំយន្តការទទួលបានមូលនិធិ ការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាប ពិការភាពនៅគ្រប់កម្រិតតាមវិស័យនានា ការប្រតិបត្តិប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការគ្រប់គ្រងទិន្នន័យ និងការចាប់ផ្តើមគម្រោងឬកម្មវិធីនានាដែលមានអាទិភាពខ្ពស់ នៅក្នុងវិស័យសំខាន់ៗដូចបានកំណត់នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងពិការភាព។
- នៅក្នុងរយៈពេលវែង(២០២១-២០២៣) ដំណាក់កាលនេះនឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១និងទី២ ដែលត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាដំណាក់កាលនៃការប្រមូលព័ត៌មានដើម្បីធ្វើការបូកសរុបនូវវឌ្ឍនភាពនៃផែនការនេះ។ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិមានភារកិច្ចផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពមកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងពង្រឹងការអនុវត្តផែនការនេះបន្តរហូតដល់ចប់អាណត្តិ។ ដំណាក់កាលនេះផងដែរ ប្រសិនបើការអនុវត្តមិនទាន់គ្រប់តាមផែនការកំណត់ ត្រូវរៀបចំផែនការរំកិល ដើម្បីឈានទៅសម្រេចផែនការខាងលើនេះឲ្យខាងតែបាន។

## ការចាត់ចែងរចនាសម្ព័ន្ធស្ថាប័ន

ក្រុមប្រឹក្សាសកម្មភាពជនពិការដែលមានតួនាទីនិងសិទ្ធិអំណាចពេញលេញ ក្នុងការសម្របសម្រួលការងារពិការភាព ហើយមានសមត្ថភាពគ្រប់គ្រាន់និងលក្ខណសម្បត្តិពេញលេញនិងដែលបានទទួលស្គាល់ជាផ្លូវការ នឹងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីគ្រប់ដៃគូអភិវឌ្ឍនានា។

នៅកម្រិតក្រសួង ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ក៏ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។ ការទទួលខុសត្រូវរបស់មន្ត្រីបង្គោលទាំងនេះនិងក្រុមការងារ ត្រូវធ្វើឲ្យច្បាស់លាស់នាពេលឆាប់ៗខាងមុខ ជាពិសេស ទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងៗទៀតក្នុងក្រសួងពាក់ព័ន្ធដើម្បីធានាថាការរៀបចំគោលនយោបាយ កម្មវិធីនិងការវិនិយោគតាមវិស័យបានគិតគូរពេញលេញពីការដាក់បញ្ចូលជនមានពិការភាព។

ក្រុមប្រឹក្សាសកម្មភាពជនពិការនៅថ្នាក់រាជធានី ខេត្ត បានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។ ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី ខេត្ត មានតួនាទីទទួលខុសត្រូវរួមលើការគ្រប់គ្រង និងតាមដានត្រួតពិនិត្យ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ជាតិ និងការគាំទ្រការងាររដ្ឋបាលពីអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសកម្មភាពជនពិការក្នុងករណីចាំបាច់។

នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំអំពីការកសាងផែនការអភិវឌ្ឍន៍នៅក្នុងបរិបទនៃការដាក់បញ្ចូលជនមានពិការភាព នឹងត្រូវដាក់ឲ្យប្រើប្រាស់ក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។ គោលការណ៍ទាំងនេះត្រូវផ្អែកលើបទពិសោធជាច្រើន ដែលទទួលបានក្នុងឆ្នាំកន្លងទៅថ្មីៗនេះ តាមរយៈគម្រោងសាកល្បងដែលភាគច្រើននៅថ្នាក់ឃុំ សង្កាត់តាមដែលអាចធ្វើទៅបាន។ គោលការណ៍ណែនាំទាំងនេះនឹងមានរួមបញ្ចូលអនុសាសន៍នានាអំពីកិច្ចសហការនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅលំដាប់ ខុសៗគ្នា (រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់) និងជាពិសេសនីតិវិធីសម្រាប់ឲ្យឃុំទទួលបានជំនាញបច្ចេកទេសអំពីពិការភាពពីការិយាល័យឬមន្ទីរនានានៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។

**ការកសាងផែនការសកម្មភាព**

ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវបង្កើតផែនការសកម្មភាពជាអាទិភាពរបស់ខ្លួន ដោយមានកំណត់ថ្លៃចំណាយសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ទៅតាមវិស័យក្រោមជំនួយបច្ចេកទេសពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ។ ផែនការសកម្មភាពទាំងនេះនឹងត្រូវបន្សុីគ្នាយ៉ាងជិតស្និទ្ធជាមួយយុទ្ធសាស្ត្ររបស់វិស័យពាក់ព័ន្ធ។ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវកសាងផែនការសកម្មភាពជាក់លាក់មួយផងដែរ សម្រាប់មុខងារសម្របសម្រួល ដែលរួមទាំងតួនាទីរបស់ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួងស្ថាប័ន។ គោលការណ៍នាំមុខសម្រាប់ការកសាងផែនការសកម្មភាពទាំងនេះ មានចែងក្នុងផ្នែក៦.២ ខាងក្រោម។

**ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទាន**

ការផ្តល់ហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ នឹងប្រព្រឹត្តទៅតាមរយៈការប្រើប្រាស់នូវគំរូផ្តល់មូលនិធិផ្សេងៗគ្នាមួយចំនួន ដោយក្នុងនោះរួមមានវិធីសាស្ត្រដែលធ្លាប់អនុវត្តកន្លងមក និងវិធីសាស្ត្រថ្មីៗដែលទាក់ទងនិងហិរញ្ញប្បទានសកម្មភាពជនមានពិការភាព។ ដូច្នេះ ចាំបាច់ជានាឲ្យមានការសម្របសម្រួលនូវគំរូហិរញ្ញប្បទានខុសៗគ្នាទាំងនេះ ដើម្បីឲ្យដៃគូដែលមានសក្តានុពលក្នុងការផ្តល់មូលនិធិ អាចយល់បានច្បាស់លាស់អំពីតម្លៃចំណាយនិងការចាត់អាទិភាពនូវសកម្មភាពនានា នៅក្រោមផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣។ ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានសកម្មភាពជនពិការ ដែលនឹងគាំទ្រដល់របៀបអនុវត្តជាកម្មវិធីសម្រាប់ការឆ្លើយតបទៅនឹងបញ្ហាពិការភាពនៅកម្ពុជា។

## ៦.២- ការបង្កើតកម្មវិធីនិងការកសាងផែនការសកម្មភាព

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ទាមទារអភិក្រមផ្អែកលើកម្មវិធីដើម្បីជានាឲ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រនិងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីផ្អែកលើបញ្ហាដែលនាំឲ្យមានពិការភាព គួរលើកទឹកចិត្តឲ្យមានសកម្មភាពនានាដែលជំរុញឬគាំទ្រដល់ការពង្រឹងបន្ថែមនូវកាលានុវត្តភាពនានាក៏ដូចជាការពង្រីកនូវអត្ថប្រយោជន៍និងផលចំណេញបន្ថែមសម្រាប់សង្គម។ សេចក្តីពិស្តារនៃផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ នេះមានចែងនៅក្នុងឯកសារដាច់ដោយឡែក។ គោលការណ៍ដែលមានចែងនៅក្នុងចំណុច ៨.១ នឹងត្រូវយកមកអនុវត្តនៅក្នុងការបង្កើតកម្មវិធីដែលនឹងត្រូវផ្អែកលើផែនការសកម្មភាពតាមវិស័យ។

**ការពង្រឹងបន្ថែមលើយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា**

ផែនការសកម្មភាពស្តីពីពិការភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមបញ្ចូលទៅក្នុងកម្មវិធីរបស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ នឹងមិនរៀបចំឡើងជាឯកសារដាច់ដោយឡែកនៅក្រសួង ស្ថាប័ននីមួយៗឡើយ។ ជាការពិត សកម្មភាពថ្មីមួយចំនួនដែលផ្តោតលើពិការភាពនឹងត្រូវស្នើឡើង ទោះបីសកម្មភាពភាគច្រើនពាក់ព័ន្ធជាមួយផែនការសកម្មភាពដែលមានស្រាប់នៅក្នុងក្រសួង ស្ថាប័នក៏ដោយ។ គ្រប់ករណីទាំងអស់ ផែនការសកម្មភាពដែលស្នើឡើងនឹងត្រូវរួមបញ្ចូលទៅក្នុងការចាត់ចែងកសាងផែនការ និងការគ្រប់គ្រងជាលក្ខណៈស្តង់ដារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប្រការនេះរួមមានទាំងការគិតគូរពិចារណាអំពីសកម្មភាពនានាដែលទាក់ទងនឹងពិការភាពក្នុងដំណើរការលើកថវិកា និងការបង្កើតសូចនាករដែលទាក់ទងនឹងពិការភាព នៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃតាមវិស័យ។

ការបង្កើតកម្មវិធីនៅក្រោមផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ក៏ផ្តោតផងដែរលើបញ្ហាទូទៅដែលពាក់ព័ន្ធនឹងបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រ កិច្ចគាំពារសង្គម ការស្រាវជ្រាវ ការលើកកម្ពស់ការយល់ដឹង ការប្រាស្រ័យទាក់ទង និងការត្រួតពិនិត្យហិរញ្ញប្បទានសម្រាប់វិស័យពិការភាព។ ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់គួរតែគិតគូរពិចារណាអំពីចំណងទាក់ទងជាមួយវិស័យដទៃទៀត នៅពេលកសាងផែនការសកម្មភាពរបស់ខ្លួន ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការនឹងជួយផ្តល់ការគាំទ្រ ដើម្បីពិនិត្យមើលចំណងទាក់ទងទាំងនេះ។

**ភាពជាដៃគូ**

ប្រការសំខាន់គឺត្រូវទទួលស្គាល់ថា ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ វិស័យឯកជន ក្រុមជួយខ្លួនឯង និងអង្គការដទៃទៀតគឺជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ពិតមែនតែផែនការយុទ្ធសាស្ត្រនេះជាឯកសាររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលផ្តោតលើការប្រើប្រាស់ធនធានសាធារណៈក្តី តែប្រការសំខាន់គឺធនធានទាំងនេះនឹងត្រូវប្រើប្រាស់ជាកាតាលីករសម្រាប់ពង្រីកសកម្មភាពនិងវិធានការនានា ឲ្យកាន់តែធំទូលំទូលាយថែមទៀតពីសំណាក់អ្នកពាក់ព័ន្ធដទៃទៀតដើម្បីឆ្លើយតបនឹងបញ្ហាពិការភាព។ ក្នុងន័យនេះ គួរលើកទឹកចិត្តឲ្យស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាទាក់ទាញដៃគូពាក់ព័ន្ធនានាឲ្យមកចូលរួមនៅក្នុងការកសាងផែនការសកម្មភាព និងកំណត់ភាពជាដៃគូនៅក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។

## ៧- ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុជាចម្បងដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ បានមកពីថវិកាជាតិ ដៃគូអភិវឌ្ឍ ដែលបានធ្វើការងារលើវិស័យពិការភាព។ រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍធ្លាប់បានផ្តល់ធនធានហិរញ្ញវត្ថុក្នុងពេលកន្លងមកនិងសន្យាជួយបន្តទៀត។ ក្រៅពីនោះបណ្តាក្រសួងស្ថាប័ន ដែលធ្វើការងារលើវិស័យពិការភាពនឹងគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ខ្លួន។ ដោយឡែកការចូលរួមបរិច្ចាគធនធានថវិកាពីសប្បុរសជននិងផ្នែកឯកជនក៏ជាការចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ផងដែរ។

## ៨- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីឲ្យផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះមានប្រសិទ្ធភាពនិងអាចវាស់វែងបាន ចាំបាច់ត្រូវធ្វើការតាមដានត្រួតពិនិត្យនិងការវាយតម្លៃដូចខាងក្រោម៖

គោលបំណងនៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ៖

- វាស់ស្ទង់ប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការងារពិការភាព។
- ពិនិត្យតាមដានសកម្មភាពកាត់បន្ថយការរើសអើងចំពោះជនមានពិការភាពនិងការលើកកម្ពស់សិទ្ធិជនពិការ ពិសេសការធ្វើឲ្យជីវភាពរស់នៅរបស់ជនមានពិការភាពមានភាពប្រសើរឡើង។
- សម្រួលឲ្យមានបច្ចុប្បន្នកម្មស៊ីចង្វាក់គ្នា នៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃលើផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ។
- ផ្តល់ព័ត៌មានដែលចាំបាច់ក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ក្រោមការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការនិងយុទ្ធសាស្ត្រអ៊ីនឈាន់ទសវត្សជនពិការ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។

## ៨.១- គោលការណ៍នានា

គោលការណ៍នានាដែលអាចពង្រឹងក្របខ័ណ្ឌនេះ រួមមាន៖

- **ការប្រើប្រាស់ប្រព័ន្ធនិងនីតិវិធីរបស់ជាតិ** ក្របខ័ណ្ឌនេះរួមបញ្ចូលជាមួយប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិ។ សូចនាករនិងនីតិវិធីតាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវពឹងផ្អែកឲ្យបានច្រើនបំផុតលើទិន្នន័យដែលបច្ចុប្បន្ននេះស្ថិតក្រោមការពិនិត្យតាមដានដោយក្រសួងពាក់ព័ន្ធ។ សូចនាករនិងនីតិវិធីទាំងនេះត្រូវតែមានសង្គតិភាពជាមួយគោលការណ៍ណែនាំរបស់ក្រសួងផែនការអំពីប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិផងដែរ។ ក្របខ័ណ្ឌនេះនឹងចាត់ជាប្រព័ន្ធនិងពង្រឹងបន្ថែមលើកិច្ចផ្តួចផ្តើមដែលកំពុងអនុវត្ត សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងរាយការណ៍អំពីពិការភាព។
- **ការបញ្ជ្រាបការតាមដានត្រួតពិនិត្យនិងការវាយតម្លៃពិការភាព ទៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ** នីតិវិធីនិងសូចនាករនានា សម្រាប់តាមដានវិធានការការឆ្លើយតប ទៅនឹងបញ្ហាពិការភាព ត្រូវរួមបញ្ចូលទៅក្នុងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិនិងត្រូវប្រើជាឯកសារយោងសម្រាប់តាមដានប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពទៅតាមវិស័យនិងផែនការសកម្មភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព** ក្របខ័ណ្ឌនេះនឹងផ្តល់ជាវិធីមួយសម្រាប់វាស់ប្រសិទ្ធភាពនិងភាពផ្តល់ផលនៃធនធានដែលប្រើប្រាស់ ដើម្បីសម្រេចតាមចំណុចដៅនានាដូចមានក្នុងគោលនយោបាយនិងផែនការសកម្មភាព ហើយនឹងកែលម្អគណនេយ្យភាពចំពោះមុខសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ។
- **ដំណោះស្រាយបញ្ហាយេនឌ័រ** ស្ត្រីនិងកុមារីមានពិការភាពច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងផលប៉ះពាល់នៃបញ្ហាពិការភាព។ ក្របខ័ណ្ឌនេះនឹងដោះស្រាយបញ្ហាសមធម៌យេនឌ័រក្នុងការធ្វើប្រតិបត្តិការដែលគិតគូរអំពីយេនឌ័រនិងពិការភាព។

## ៨.២- វិធីសាស្ត្រ

សូចនាករនានាសម្រាប់ការដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក៏ត្រូវតែកំណត់ផងដែរ។ ផែនការមួយនឹងត្រូវរៀបចំឡើងដែលចែងអំពីសកម្មភាពនានា ការអភិវឌ្ឍសមត្ថភាព ការកំណត់តម្លៃចំណាយសម្រាប់ការអនុវត្តរយៈពេលវែង និងការបញ្ជ្រាបក្របខ័ណ្ឌនេះនៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ។

នៅក្នុងរយៈពេលវែង(២០២១-២០២៣) ក្របខ័ណ្ឌនេះនឹងត្រូវដាក់ឲ្យក្រសួងពាក់ព័ន្ធនិងគម្រោងនានាយកទៅអនុវត្តនៅតាមវិស័យអាទិភាពដែលការជ្រើសរើសនេះនឹងធ្វើឡើងអាស្រ័យលើសមត្ថភាពនិងធនធានដែលមាន។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការក៏មានភារកិច្ចទទួលខុសត្រូវ លើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក្រោមការសម្របសម្រួលនិងពិនិត្យពីថ្នាក់ដឹកនាំក្រុមប្រឹក្សាសកម្មភាពជនពិការអំពីវឌ្ឍនភាពផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពប្រចាំឆ្នាំផងដែរ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀតដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងដំណើរការនេះ ត្រូវឯកភាពគ្នាលើសូចនាករ នីតិវិធី និងការទទួលខុសត្រូវនានាលើការប្រមូលទិន្នន័យ។ ត្រូវសិក្សាអំពីភាពជាដៃគូមួយជាមួយគ្រឹះស្ថានស្រាវជ្រាវនិងគ្រឹះស្ថានសិក្សានានា សម្រាប់គ្រប់គ្រងបណ្តាញការងារនៃទីតាំងទាំងឡាយ សម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃរយៈពេលវែង។

## ៨.៣- ការគ្រប់គ្រងនិងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវដើរតួនាទីជាអ្នកសម្របសម្រួលការកសាងការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។

ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានីខេត្ត មានភារកិច្ចជួយសម្របសម្រួលការផ្លាស់ប្តូរទិន្នន័យ និងបញ្ជ្រាបផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣នេះ នៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ។

វឌ្ឍនភាពនៃការតាមដានត្រួតពិនិត្យនិងសរសេររបាយការណ៍ស្របទៅនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ គឺជាមូលដ្ឋានដ៏សំខាន់ដើម្បីធានាថាជីវិតជនមានពិការភាពនៅកម្ពុជាត្រូវបានប្រសើរឡើង ដើម្បីវាយតម្លៃការអនុវត្តនៅពាក់កណ្តាលអាណត្តិនិងការវាយតម្លៃចុងក្រោយ។

ការរៀបចំឲ្យមានប្រព័ន្ធទិន្នន័យសមស្របស្តីពីពិការភាព ដោយមានរំលេចឬញែកទៅតាមតម្រូវការប្រើអនុសញ្ញាសិទ្ធិជនពិការនិងអនុសញ្ញានានាដែលកម្ពុជាជារដ្ឋភាគី គឺជាការចាំបាច់ ដើម្បីសម្រួលដល់ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា ដៃគូនិងអង្គការសហប្រជាជាតិ។ នៅពេលដែលទិន្នន័យជាតិស្តីពីពិការភាពអាចរកបាន ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព នឹងត្រូវធ្វើបច្ចុប្បន្នកម្មដើម្បីឲ្យឆ្លើយតបទៅនឹងស្ថិតិដែលរបាយការណ៍ត្រូវតែស៊ីគ្នាទៅនឹងទិន្នន័យថ្មីនោះ។

### ស្ថាប័នបង្គោល

គ្រប់ក្រសួង ស្ថាប័ន អង្គភាពទាំងអស់មានការទទួលខុសត្រូវបឋមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយឡែកត្រូវអនុវត្តសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធទៅនឹងវិស័យនិងជំនាញនៃក្រសួង ស្ថាប័ន អង្គភាពនីមួយៗនៅគ្រប់ទិសដៅជាយុទ្ធសាស្ត្រទាំង៩។ ក្រសួង ស្ថាប័ន អង្គភាពត្រូវវាយតម្លៃអំពីគោលនយោបាយនិងយុទ្ធសាស្ត្រដែលមានស្រាប់របស់ខ្លួនជាមួយនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ដើម្បីកំណត់ពីវឌ្ឍនភាពនៃផ្នែកនីមួយៗ ដែលមិនទាន់បានធ្វើនិងកែតម្រូវឲ្យបានស្របគ្នា។ គ្រប់ក្រសួង ស្ថាប័ន អង្គភាព និងដៃគូពាក់ព័ន្ធត្រូវរាយការណ៍អំពីការសម្រេចបានលើតួនាទីភារកិច្ចរបស់ខ្លួនជារៀងរាល់ឆ្នាំ។

### យន្តការ

ក្រុមប្រឹក្សាសកម្មភាពជនពិការនឹងរៀបចំការតាមដានដំណើរការ និងផ្តល់អនុសាសន៍ជាក់លាក់ ដើម្បីជំរុញការយកចិត្តទុកដាក់របស់គ្រប់ភាគីពាក់ព័ន្ធ។ ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពលើផែនការ

យុទ្ធសាស្ត្រជាតិស្តីពីពិការភាពតម្រូវឲ្យក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនផ្តល់ជូននូវរបាយការណ៍និងព័ត៌មានពាក់ព័ន្ធឲ្យបានទៀងទាត់បំផុត។

**ការចូលរួមពីសង្គមស៊ីវិល**

កិច្ចប្រជុំជាទៀងទាត់ជាមួយតំណាងសង្គមស៊ីវិលត្រូវរៀបចំឡើង ដើម្បីតាមដាននិងរាយការណ៍ អំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ តំណាងសង្គមស៊ីវិលទាំងនោះនឹងត្រូវបានអញ្ជើញឲ្យចូលរួមឬផ្តល់ព័ត៌មានដល់កិច្ចប្រជុំនោះតាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ។

## ៩- សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ជាវិធានការអនុវត្តបន្តក្នុងការឆ្លើយតបទៅនឹងគោលនយោបាយជាតិ ដោយផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ជាការឆ្លើយតបទៅនឹងបញ្ហាពិការភាព និងតម្រង់ទិសឆ្ពោះទៅរកការលើកកម្ពស់វិស័យពិការភាពនៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ជាផែនទីចង្អុលផ្លូវក្នុងការដឹកនាំនិងភាពជាម្ចាស់លើវិស័យពិការភាពឆ្លើយតបទៅនឹងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នៃរាជរដ្ឋាភិបាលកម្ពុជា និងឧត្តមប្រយោជន៍របស់បងប្អូនជនមានពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការបំពេញកាតព្វកិច្ចអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រ អ៊ីនឈាន់ ***"ធ្វើឲ្យសិទ្ធិក្លាយជាការពិត"*** ទសវត្សជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០១៣-២០២២ និងការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។

## សទ្ទានុក្រម

**ការអភិវឌ្ឍដែលឈរលើការដាក់បញ្ចូលនៅតាមសហគមន៍** សំដៅដល់វិធីសាស្ត្រមួយឆ្ពោះទៅរកការអភិវឌ្ឍ ដែលធានានូវការចូលរួមភាពស្មើគ្នារបស់ប្រជាជនគ្រប់រូបក្នុងសហគមន៍ដោយគ្មានការរើសអើងក្នុងគ្រប់ សកម្មភាព។ គោលការណ៍ណែនាំស្តីពីការងារស្តារលទ្ធភាពពលកម្មតាមសហគមន៍របស់អង្គការសុខភាព ពិភពលោក កំណត់គោលការណ៍នេះជាយុទ្ធសាស្ត្រមួយ និងការអភិវឌ្ឍដែលឈរលើការដាក់បញ្ចូលនៅតាម សហគមន៍ ជាគោលដៅក្នុងការសម្រេច។

**ការសម្របសម្រួលសមស្រប** សំដៅដល់ការកែឲ្យសមរម្យនិងចាំបាច់ និងការកែតម្រូវដែលមិនបង្ខំឲ្យការ ទទួលខុសត្រូវមានភាពវិសមាមាត្រឬមិនត្រឹមត្រូវ ដែលមានភាពចាំបាច់តែក្នុងករណីពិសេស ដើម្បីធានាដល់ ជនមានពិការភាពឲ្យទទួលបាន និងប្រើប្រាស់បាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរ លើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

**ការបង្កលក្ខណៈងាយស្រួល** សំដៅដល់ការផ្តល់លទ្ធភាពដល់ជនមានពិការភាពក្នុងការរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញ តាមរយៈការទទួលបាននូវបរិស្ថានរូបវន្ត ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយ ធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ទំនាក់ទំនង និងសេវាកម្មផ្សេងទៀត ដែលបើកឬផ្តល់ឲ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុងទាំងនៅតាមទីជនបទ។

**ការងារស្តារលទ្ធភាពពលកម្មតាមសហគមន៍** សំដៅដល់យុទ្ធសាស្ត្រសម្រាប់ការស្តារលទ្ធភាពពលកម្ម ឱកាស ស្មើភាពគ្នា ការកាត់បន្ថយភាពក្រីក្រ និងការដាក់បញ្ចូលទៅក្នុងសង្គម ដោយសារតែវាទាក់ទងទៅនឹងជនមាន ពិការភាព។ ដំណើរការការងារស្តារលទ្ធភាពពលកម្មតាមសហគមន៍ មានទិសដៅឈានឆ្ពោះទៅរកការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម ដែលមានការដាក់បញ្ចូលជនមានពិការភាពឲ្យចូលរួមគ្រប់សកម្មភាពដូចជនមិនមានពិការ ភាពដែរនៅក្នុងគេហដ្ឋាននិងសហគមន៍របស់គាត់។ ការងារស្តារលទ្ធភាពពលកម្មតាមសហគមន៍ក៏មានទិសដៅ ផងដែរក្នុងការកសាងនិងរក្សាការគាំទ្រដល់ជនមានពិការភាព មានន័យថាកម្មវិធីស្តារលទ្ធភាពពលកម្មតាម សហគមន៍ត្រូវតែមាននិរន្តរភាពនិងចៀសវាងជាបន្ទុកនៃការគាំទ្រក្នុងរយៈពេលខ្លីមកពីខាងក្រៅ។

**កាកសំណល់ជាតិផ្ទុះពីសង្គ្រាម** សំដៅដល់ពាក្យមួយដែលប្រើប្រាស់ក្នុងការពិពណ៌នាជាតិផ្ទុះដែលមានការគំរាម កំហែង នៅសល់ក្រោយពីជម្លោះក្នុងសង្គម ដែលអាចមានមីន គ្រាប់បែកចង្កោម គ្រាប់បែកថ្មេ និងកាកសំណល់ មិនទាន់ផ្ទុះដែលបន្តគ្រោះថ្នាក់ដល់មនុស្សគ្រប់រូប និងជាឧបសគ្គដល់ការអភិវឌ្ឍសហគមន៍។

**ការស្តារមុខរបរនិងវិជ្ជាជីវៈ** សំដៅដល់ការផ្តល់ជំនាញនិងមុខរបរឡើងវិញ ស្របតាមប្រភេទនិងកម្រិតពិការភាព។

**កម្មវិធីស្ពានចម្លងបន្តជំនាញ** សំដៅដល់កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមឬថ្មីដល់ជនមានពិការភាពដែល កំពុងធ្វើការ ដើម្បីទទួលបាននូវជំនាញបន្ថែមនៅក្នុងអំឡុងពេលធ្វើការដើម្បីអភិវឌ្ឍជំនាញអាជីព(ឧទាហរណ៍ ការអភិវឌ្ឍពីកម្មករគ្មានជំនាញទៅកម្មករមានជំនាញ)។

**កម្មវិធីបណ្តុះបណ្តាលជំនាញ** សំដៅដល់កម្មវិធីបណ្តុះបណ្តាលផ្អែកលើមុខរបរនៅពេលបានបញ្ចប់ពេញលេញ និងវាយតម្លៃរួច បានជាក្រេឌីត ឈានឆ្ពោះទៅដល់ការទទួលបានគុណវុឌ្ឍិពេញលេញឬផ្នែកនៃគុណវុឌ្ឍិ ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

**កីឡាប៉ារ៉ាអូឡាំពិក** សំដៅដល់ប្រភេទកីឡាសម្រាប់ជនពិការភាពទូទៅ លើកលែងតែជនខ្សោយសតិបញ្ញា ពិការខួរក្បាល។ Ms

**កីឡាស្បៀស្សាល់អូឡាំពិក** សំដៅដល់ប្រភេទកីឡាសម្រាប់ជនមានពិការភាពជនខ្សោយសតិបញ្ញា។ គោលការណ៍ណែនាំសំណុំសកម្មភាពអប្បបរមា សំដៅដល់គោលការណ៍ណែនាំទូលំទូលាយស្តីពីការផ្តល់សេវាថែទាំសុខភាពនៅតាមមណ្ឌលសុខភាព។

**កម្រងសំណួរពិការភាពវ៉ាស៊ីនតោន** សំដៅដល់កម្រងសំណួរដែលបានរៀបចំឡើងដោយក្រុមការងារពិការភាពរបស់អង្គការសហប្រជាជាតិនៅទីក្រុងវ៉ាស៊ីនតោនក្នុងគោលគោលបំណងកំណត់រកអត្រាពិការភាពកម្រិតអន្តរជាតិមួយសម្រាប់ប្រមូលទិន្នន័យពិការភាពតាមរយៈការធ្វើអង្កេតឬជំរឿន។

**ក្រុមជួយខ្លួនឯង** សំដៅដល់ក្រុមជនមានពិការភាពដែលបានបង្កើតឡើងដើម្បីគាំទ្រគ្នាទៅវិញទៅមកដែលធ្វើឲ្យមានដំណើរការដោយជនមានពិការភាពដែលមានឆន្ទៈ ដើម្បីបង្កលក្ខណៈឲ្យអ្នកជិតខាងក្នុងសហគមន៍ក្លាយជាអ្នកដែលមានឯករាជ្យភាពនិងមានទំនុកចិត្ត។

**គោលការណ៍ណែនាំសំណុំសកម្មភាពអប្បបរមា** សំដៅដល់គោលការណ៍ណែនាំទូលំទូលាយស្តីពីការផ្តល់សេវាថែទាំសុខភាពនៅតាមមណ្ឌលសុខភាព។

**គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ** សំដៅដល់វិទ្យាស្ថាន មជ្ឈមណ្ឌល សាលាមធ្យមសិក្សាបច្ចេកទេសទាំងឡាយណា ដែលផ្តល់វគ្គសិក្សាពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

**ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស** សំដៅដល់ជនទាំងឡាយណាដែលមានពិការភាពហើយត្រូវការគាំទ្របន្ថែមនិងវិធីសាស្ត្របង្រៀនដើម្បីសម្រួលដល់ការសិក្សារបស់ពួកគេ។

**ជនមានពិការភាព** សំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឲ្យមានការចូលរួមយ៉ាងពេញលេញនិងមានប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន។

**ជំនួយផ្នែកបុគ្គល** សំដៅដល់ការផ្តល់មនុស្សដើម្បីថែទាំដល់ជនមានពិការភាពធ្ងន់ធ្ងរ។

**និយាមក្រមសីលធម៌** សំដៅលើការគោរពវិជ្ជាជីវៈសុខាភិបាល ជាពិសេសអ្នកផ្តល់សេវាថែទាំសុខភាព ដូចជាគិលានុបដ្ឋាកយិកា។

**បរិស្ថានគ្មានពិការភាព** សំដៅដល់វិធីសាស្ត្រមួយដែលប្រើប្រាស់គោលការណ៍ដើម្បីឆ្លើយតបបញ្ហាពិការភាពដោយឈរលើគំរូសង្គមដើម្បីកាត់បន្ថយសំពាធនិងឧបសគ្គរបស់ជនមានពិការភាព និងស្វែងរកបន្ថែមនូវការទទួលខុសត្រូវនិងទំនួលបន្ទុកពីភារកិច្ចរំកែពន់និងសហគមន៍ទាំងមូល។ បរិស្ថានគ្មានពិការភាពស្វែងរកដើម្បីបង្កើតបរិស្ថានដែលគ្មានឧបសគ្គសម្រាប់ជនមានពិការភាព។ វាអាចទាក់ទងទៅនឹងបរិស្ថានរូបវន្ត បរិស្ថានសង្គម និងបរិស្ថានផ្លូវចិត្តរបស់ជនមានពិការភាព។

**បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** សំដៅដល់ការរៀបចំបង្កលក្ខណៈងាយស្រួលនៅតាមទីកន្លែងសាធារណៈនិងឯកជនសម្រាប់ជនមានពិការភាព អាចប្រើប្រាស់បានដូចជា សំភារៈឧបករណ៍ការិយាល័យ ជម្រាល បង្កន់ បន្ទប់ទឹក ចំណតយានយន្ត ស្លាកសញ្ញា។ល។ ទាំងខាងក្នុងនិងខាងក្រៅអគារ។

**បុននីតិសម្បទា** សំដៅដល់ការឧបត្ថម្ភដល់ជនដែលប៉ះពាល់ធ្ងន់ធ្ងរ ដោយបាត់បង់ទ្រព្យសម្បត្តិផលិតកម្ម ប្រាក់ចំណូល ការងារឬប្រភពនៃជីវភាពរស់នៅ ដើម្បីបន្ថែមលើសំណងចំពោះទ្រព្យសម្បត្តិដែលយកក្នុងបំណងស្តារឡើងវិញទាំងស្រុងនៃស្តង់ដាជីវភាពរស់នៅនិងគុណភាពជីវិត។ សំណងចំពោះទ្រព្យសម្បត្តិនានា ជាទូទៅមិនគ្រប់គ្រាន់ដើម្បីសម្រេចឲ្យបានបុននីតិសម្បទាពេញលេញឡើយ។

**បុរេវិនិច្ឆ័យហានិភ័យគ្រោះមហន្តរាយ** សំដៅដល់ការប៉ាន់ប្រម៉ាណទុកជាមុននូវផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះមហន្តរាយ។

**ទីកន្លែងសាធារណៈ** សំដៅដល់បរិវេណ ទីតាំង អគារ និងមធ្យោបាយដឹកជញ្ជូននានាជាកម្មសិទ្ធិរបស់រដ្ឋ សាធារណៈឬឯកជនដែលបើកទូលាយនិងផ្តល់សេវាដល់សាធារណជនទូទៅជាអាទិ៍ ក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ កន្លែងលម្ហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកំសាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព អាហារដ្ឋាន ប្រព័ន្ធដឹកជញ្ជូន។

**មូលដ្ឋានសុខាភិបាល** សំដៅដល់ប៉ុស្តិ៍សុខាភិបាល មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។

**យុទ្ធសាស្ត្រអ៊ីនឈាន់** សំដៅដល់ឈ្មោះយុទ្ធសាស្ត្រទស្សវត្សជនមានពិការភាព២០១៣-២០២២ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ធ្វើឲ្យសិទ្ធិក្លាយជាការពិត បានអនុម័តនៅទីក្រុងអ៊ីនឈាន់ សាធារណរដ្ឋកូរ៉េ ក្នុងឆ្នាំ២០១២ ដែលកម្ពុជាជាប្រទេសហត្ថលេខី។

**វិភាគប្រភេទអាជីវកម្ម** សំដៅដល់ការគិតគូរវិនិច្ឆ័យពីមុខរបរ មុខជំនាញ ស្របតាមកម្រិត និងប្រភេទពិការភាពរបស់ជនមានពិការភាព។ ឧទាហរណ៍ ជនមានពិការភាពដោយខូចជើងទាំងពីរ អាចក្លាយជាអ្នកជួសជុលវិទ្យុ ទូរទស្សន៍។

**សន្តតិកម្ម** សំដៅដល់ការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលណាម្នាក់ដែលស្លាប់ទៅឲ្យជនណាម្នាក់ឬច្រើននាក់ដែលហៅថាទាយាទឬសន្តតិជន។

**ស្តារនីតិសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ** សំដៅដល់ការធ្វើឲ្យស្ថានភាពជនមានពិការភាពបានប្រសើរឡើងផ្នែករាង្គកាយ សតិអារម្មណ៍ មានជំនាញវិជ្ជាជីវៈ និងមានការងារមុខរបរ។

**ស្តារលទ្ធភាពពលកម្មកាយសម្បទា** សំដៅដល់ការធ្វើឲ្យមុខងាររបស់សរីរាង្គនិងញាណដឹងដែលបានបាត់បង់មានភាពប្រសើរឡើងតាមរយៈការព្យាបាលដោយចលនា ផ្តល់ឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលហេដ្ឋារចនាសម្ពន្ធ័រូបវន្ត ការអប់រំដើម្បីអាចរស់នៅដោយឯករាជ្យ និងអាចចូលរួមរាល់សកម្មភាពក្នុងសង្គម។

**ស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ** សំដៅដល់ការកែលម្អសរីរាង្គមិនប្រក្រតីតាមរយៈការវះកាត់ ការដាក់ថ្នាំសណ្តំ ការផ្តល់ឱសថ ការថែទាំរបួស និងការព្យាបាលដោយចលនា។

**ហានិភ័យហិរញ្ញវត្ថុសុខាភិបាល** សំដៅដល់ការរៀបចំមូលនីធិសមធម៌និងការធ្វើអន្តរាគមន៍ហិរញ្ញប្បទាន ដើម្បីជួយក្នុងការថែទាំសុខភាពជនក្រីក្រ។

**អក្សរប្រៃយ៍** សំដៅដល់អក្សរផុសដែលជនមានពិការភាពភ្នែកអាចអានបានតាមរយៈការប្រើចុងម្រាមដៃស្ទាប អក្សរនេះបង្កើតឡើងដោយលោកល្វីស ប្រៃយ៍ Louis Braille ជនជាតិបារាំងដែលជាជនមានពិការភាពភ្នែកផ្ទាល់នៅអំឡុងឆ្នាំ១៨៥៤។

**អង្គការជួយខ្លួនឯង** សំដៅដល់អង្គការមួយដែលដំណើរការដោយជនមានពិការភាពដែលមានឆន្ទៈដើម្បីបង្កលក្ខណៈឲ្យអ្នកជិតខាងក្នុងសហគមន៍ ក្លាយជាអ្នកដែលអាចមានអំណាចរបស់ខ្លួនឯងឯករាជ្យនិងទំនុកចិត្តផ្ទាល់ខ្លួន។

**បរិយាបន្ន** សំដៅដល់លើការលើកកម្ពស់ស្ថានភាពរបស់បុគ្គលនិងក្រុមនានា ក្នុងការចូលរួមនិងទទួលផលពីសកម្មភាពនានាដោយមិនរើសអើង។

**ឧបករណ៍ជំនួយ** សំដៅដល់គ្រឿងឧបករណ៍ពិសេសសម្រាប់សម្រួលការលំបាករបស់ជនមានពិការភាព ឧទាហរណ៍រទេះរុញឬឈើច្រត់ជួយសម្រួលដល់ការធ្វើដំណើរដល់ជនដែលមានបញ្ហាចលនា ឬវ៉ែនតាជួយសម្រួលដល់ជនដែលមានបញ្ហាក្នុងការមើល។








**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ**

: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ

: +៨៥៥-២៣-៧២៧-៤២៨

: +៨៥៥-២៣-៧២៧-៤២៦

: info@dac.org.kh

: ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council

: www.dac.org.kh